# វគ្គទីមួយ
# បងស្រី

ម៉ោងប្រហែលបួនរសៀល លើនឯផ្លូវ កាត់ភូមិព្រៃកូនខ្លា...

រថយន្តឡៃនគ្រូសឺរឌីថ្មីស្រឡាងមួយបោះពួយយ៉ាងលឿនស្លេវ ពីក្រុងបាត់ដំបងសំដៅទៅរកទិសភ្នំសំពៅ ហាក់កំពុងសំញែងឫក អង្គបង្អួតថាលើផ្លូវនេះមានតែអញ ស្រាប់តែភ្លាត់ស្នៀតបរចៀស គោដាច់កន្លះមួយរត់មកពីណាមិនដឹង រត់កាត់ទទឹងថ្នល់ បណ្ដាលឲ្យម្ចាស់រថយន្តជ្រុលចង្កូតចុះពីផ្លូវ ធ្លាក់ចុះទៅក្នុងប្រឡាយស្នាមភ្លោះគ្រាំៗ អូសទៅឆ្ងាយពីដីគោកប្រហែលជិត៨ម៉ែត្រ ស្ទុះកង់ក្នុងភក់ វិលទៅមុខលៃងរួចតែម្ដង ។ នោះសំណាងល្អ ហើយដែលរដូវនេះជារដូវវស្សា មានទឹកភ្លៀងដក់តាមប្រឡាយសងខាងផ្លូវ កុំអីមិនដឹងជាគ្រោះថ្នាក់ដល់ផ្ទះអ្នកស្រុក តាមបណ្ដោយផ្លូវនេះអស់ប៉ុន្មានខ្នងទៅហើយទេ ។

ថៃងនេះ រថយន្តនោះមានផ្ទុកបុរសតែម្នាក់ កុំអីអ្នកជិះជាមួយនោះមិនដឹងជាភ័យលោះព្រលឹងរត់ដល់ក្រហែងណាទៅហើយក៏មិនដឹង ។ បុរសអ្នកបើកបរនោះ មួលកញ្ចក់បង្អួចចុះហើយស្រែកហៅ

អ្នកស្រុកថា ៖
- ឪយ! អាណាគេនៅម្តុំនេះ មកជួយអញបន្តិចឪយ!
យី! សំនឹគ្រោតគ្រាតណាស់តើហ៏! អ្នកស្រុកម្តុំនោះឈរមើលរហង់ តែគ្មាននរណាគេនឹកនាមកជិតបុរសនោះម្នាក់សោះ ។
- យី! អញហៅអោយជួយអញផង មិនឮទេ? ឃើញទេ? ឡានអញវាជាប់ផុង ទៅណាមិនរួច ។
អ្នកស្រុកទាំងនោះជ្រួញចិញ្ចើមដាក់គ្នា ។ ដំបូងៗ គេនាំគ្នារត់ស្ទើរស្របំរុងថាទៅរកជួយទៅហើយ ទទួលឮពាក្យគ្រោតគ្រាតរបស់បុរសនោះ ក៏អស់ទឹកចិត្តលែងចង់ជួយតែម្តង ។ តាចាស់ម្នាក់មានប្រសាសន៍ឡើងថា ៖
- បុរសហ្នឹងប្រហែលជាស្រវឹងហើយទើបរៅកវ៉ាក់មិនដឹងអីដូច្នេះ កុំទៅរវល់នឹងគេអី! ទុកអោយគេចមចយការស្រវឹងពីខួរសិនទៅ ចាំយើងគិតទៀត ។ បើយើងទៅជួយនៅពេលនេះ គុណឡាស់ក្លាយជាទោសមិនខាន ។
អ្នកស្រុកបួនដប់នាក់នោះ ក៏បំបែកជួរអស់ទៅ មិនមាននរណាហុចដៃជួយបុរសយើងទេ ។
- ឪយ! អាក្មេងក្មាងម្តុំនេះ មានអាណាមានដៃមានជើងខ្លះទេ? មកជួយអញម៉ាភ្លែត! ចាំអញអោយពីរបីម៉ឺនចាយ...
បុរសនោះបើកទ្វាររថយន្តស្រែកមករកអ្នកស្រុក ដោយមានទាំងធ្វើមុខខ្មើមរអើមទឹកភក់ ដែលនៅពីក្រោមរថយន្តនោះផង ។ ការពិត រថយន្តកប់ក្នុងទឹកប្រឡាយយ៉ាងឆ្ងាយពីផ្លូវថ្នល់ ជំរៅដល់ជង្គង់ ។ ថែនឡរថយន្តនោះទ្រង់ខ្ពស់បន្តិច កុំអីម្ចាស់ឡានត្រូវជ្រមុលជ្រមកជ្រកក្នុងទឹកល្បក់ខ្លះមិនខាន ។ ឯអ្នកបើកបរនោះវិញ មានវ័យប្រមាណសែបួយ ស្លៀកខោអាវឡូយឆាយ តែគ្មានស្ងួហ្វ័រ



បើកជូនលោកសោះ មិនដឹងថាមកពីហេតុអីទេ ។
គ្រាន់តែឮសូរថាបានលុយចាយពីរបីម៉ឺន ក្មេងប្រុសពីរនាក់អាយុប្រហែល១០ឆ្នាំ រត់ស្រទៅជួយ ។
- ងាប់ហើយ ពួកឯងល្អិតៗណាស់ សែងអញមិនរួចទេ! ទៅហៅពួកអាធំៗជាងហ្នឹងបានទេ?
- ងាប់ហើយពូអើយ! នៅម្តុំនេះ គ្មានពួកអាធំៗដែលពូឯងស្រែករកនោះឡើយ (ក្មេងម្នាក់ឆ្លើយឡើង)
- អូហ៏ ហើយពួកវាទៅណាអស់ហើយ?
- ទៅរកស៊ីនោះអី នៅសល់តែអាល្អិតៗនេះឯង ឥលូវ ទៅឬមិនទៅ? បើទៅ យើងជួយសែងពូទៅដាក់លើគោក ។ បើមិនទៅទេ នៅចាំមនុស្សធំគេមកជួយពូឯងទៀតទៅ ។
បុរសនោះសម្លឹងក្មេងៗ ឃើញតូចៗពេក មិនហ៊ានអោយវាជួយសែងគាត់ទេ ក្រែងដួលធ្លាក់ទឹកប្រឡាក់ខោអាវថ្មីរបស់គាត់ ៖
- អញមិនទៅទេ ចាំម៉ាសន្ទុះទៀតក៏បានដែរ ។
ក្មេងពីរនាក់ក៏រត់ចេញទៅ ។ ស្រាប់តែមានយុវជនម្នាក់មាឌធំខ្ពស់គួរសមគ្រាន់តែរាងស្គមបន្តិច អាយុប្រហែល១៧ឆ្នាំ ដើរមកពីខាងណាមិនដឹង ក៏មកដល់ទីនោះដែរ ។
- នែ៎ឪយ! មកជួយអញបន្តិចឪយ!
យុវជននោះបែរមើលបុរសចំណាស់ ហើយក៏ជ្រួញចិញ្ចើម ៖
- ពូឯង ហៅនរណាគេ ឪយៗ?
- គឺហៅឯងហ្នឹងណា៎!
- ខ្ញុំមិនមែនឈ្មោះឪយទេ ហើយក៏មិនមែនកូនចៅរបស់ពូឯងដែររឿងអីដែលខ្ញុំត្រូវទៅជួយពូឯងផង?
- យី! ក្មេងនេះ អត់ចិត្តមែននី!

- ពួឯងក៏អត់យ៉ាប់ដូចតែគ្នាហ្នឹង ចាស់ហើយនិយាយស្ដីពិបាកស្ដាប់គួរអោយខ្មាស់ក្មេងណាស់ ។
- យើ! ឯងមានមុខស្អី មកហ៊ានស្ដីអោយអញ ?
- ទៅអត់ស្អីម៉ាអាមុខនោះ ? មុខអ្នកក្រសំបូរជាងអ្នកមានទៅទៀត មានតាំងពីមុខឆ្កែ មុខស្វា មុខសំពោចអីក៏មានដែរ ។ ពួកអ្នកមានតើហ៊ីដែលវាអត់ ព្រោះវាមានតែមុខដូចយក្សតែម្យ៉ាង មិនគួរអោយរាប់ជាគ្នាទេ ព្រោះពួកអាមុខយក្សអស់នេះវាចូលចិត្តក្រញីក្បាលសត្វស៊ីជាចំណីណាស់ ។ ដូច្នេះ អាមុខសត្វដូចយើងមិនគួរនៅបៀតទេ ខ្លាចពួកអាមុខយក្សវាខាំស៊ី!!

ថាហើយ យុវជននោះក៏ដើរប្រុយទៅ លែងអើពើ ធ្វើអោយបុរសនោះម្ជួម៉ៅតែម្ដង តែក៏មិនអាចធ្វើអីបានឡើយ ៖
- យីអើ! សាអ្នកស្រុកម្ដុំនេះ អីក៏អត់ចិត្តម៉េះទ្រី ? គ្មានអាណាគេចង់បានលុយទេហ្អី បានជាមិនឃើញមកជួយអញម្នាក់យ៉ាងហ្នឹង ?

បុរសនោះរអ៊ូឡូងៗ ធ្វើមើលតែប្រាក់របស់គាត់ជាអាទិទេពន៍អស្ចារ្យអញ្ចឹង មិនដឹងថាមារយាទនិងសំដីរបស់គាត់នោះ វាយ៉ាប់ដល់ណាហើយទេ រហូតដល់អ្នកស្រុកម្ដុំនោះអស់ទឹកចិត្តនឹងមកជួយគាត់អស់រលីង ។ រីឯរថយន្តរបស់គាត់ក៏ឈ្លក់ទឹករលត់ម៉ាស៊ីនឈឹងរួចហើយក៏កប់ផុងក្នុងទឹកប្រឡាយ ឆ្ងាយពីចញ្ចើមថ្នល់ដល់ទៅជិត៨ម៉ែត្រ ។ បើនឹងអោយចុះដើរ គាត់ទៅមិនរួចទេ ព្រោះទឹកនៅក្នុងប្រឡាយនោះក្រខ្វក់ណាស់ ម្យ៉ាងគាត់កំពុងតែខ្ពើមភក់ស្រាប់ផង ។ ម្ដុំនោះ មានផ្ទះអ្នកស្រុកច្រើនគួរសមដែរ ប៉ុន្តែទំនងជាអ្នកគ្រាន់បើបន្តិចផង មិនសូវជាអត្តខាត់ប៉ុន្មានទេ ព្រោះផ្ទះគេមួយៗជាផ្ទះឈើ ឬផ្ទះឥដ្ឋមានលក្ខណៈសមសួន ។ ប្រហែលជាដូច្នេះទេដឹង បានជាគេមិនរវីរវល់ហ្នឹងប្រាក់របស់ចៅកែម្នាក់ហ្នឹង ។



មួយស្របក់ក្រោយមក មានមាណវីអាយុប្រមាណ១៥ឆ្នាំស្លៀកខោអាវប្រុស ជិះកង់ដឹកចេកពីរបីស្ទង កាត់តាមនោះ ។
- អ៊ី! មីនាង! (បុរសនោះស្រែកហៅ)

មាណវីក៏ឈប់កង់អែបខាង សួរថា ៖
- ហើយពូអផ្សុកខ្លាំងណាស់ទៅហ្អី បានជាបើកឡានចុះទៅលេងទឹកប្រឡាយ ? ដឹងទេ ថានោះជាកន្លែងខ្ញុំចិញ្ចឹមកូនត្រីក្រឹមលក់ ?
- ហ្អា៎ស ? អាណាគេថាទឹកប្រឡាយនេះជាបរិវេណដីរបស់នាង ?
- មាននរណាថា ? គឺខ្ញុំនេះអីថា... សងលុយភ្លាមមក៍!
- ចុមយក្ស! ឃើញមុខទារលុយមើលតែទារតុងទីន ។ នែ៎ បើនាងចង់បានមែន ទៅជួយយកឈើមកដាក់កល់បន្តធ្វើស្ពានអោយយើងដើរឆ្លងបន្តិចមក យើងមានការប្រញាប់ ។
- យី! ងាប់ត្រីក្រឹមរបស់ខ្ញុំទាំងហ្វូង មិនទាន់អោយលុយផង មករកប្រើស្អី ? នែ៎ ពូ! បើចង់ប្រើអោយខ្ញុំជួយចម្លងពូទៅដាក់នឹគោកនោះ ទាល់តែគិតលុយរឿងត្រីក្រឹមសិន ។
- ហើយឯងមានគ្នាប្រុសៗមាឌធំៗខ្លះទេ ?
- មិនអត់ទេ តែពូត្រូវការគេធ្វើអី ?
- គឺអោយគេជួយសែងអញដាក់លើគោក ។
- ម៉ាអារឿងប៉ុនហ្នឹងមានទៅពិបាកស្អី ?
- អញ្ចឹង ទៅហៅអោយបន្តិចមក៍!

ស្រាប់តែមាណវីនោះលាតដៃបក់ម្រាមរវិចៗ ទំនងទារលុយ ៖
- ចុះឯណាថ្លៃត្រីក្រឹម... នឹងថ្លៃរត់ការ ?
- យី! គ្រាន់តែឲ្យទៅហៅមនុស្សមកជួយក៏ទារលុយដែរទ្រី ?
- នេះសម័យជឿនលឿនរបស់ប្រទេសយើងណា៎ពូ រត់ការស្អីក៏គេទារលុយថ្លៃទឹកតែដែរ ពូមិនដឹងទេហ៍ ?

ដោយទាល់ច្រក បុរសនោះក៏ទាញកាបូបលុយចេញមក ។

- អញគ្មានរាយទេ មីនាង! មានតែក្រដាសមួយរយដុល្លារ ។

- អញ្ចឹង ជង្គង់ខ្ញុំក៏គ្មានកម្លាំងនឹងដើរធ្វើការដែរ!

នាងក៏ហាក់ឡើងជិះកង់វិញ ។ ស្រាប់តែបុរសចំណាស់ឃាត់ ៖

- នែ៎... ឈប់សិន! និយាយគ្នាមិនទាន់ចប់ឯណា? មកនេះ! យកលុយនេះទៅដូរទៅ ហើយកាច់យកបីដុល្លារទៅ សល់ប៉ុន្មានយកមកអោយអញវិញ ។

ធិតានោះបញ្ឈរកង់ទុក រួចក៏ដើរលុយទឹកទៅទទួលលុយនោះ ស្រាប់តែជ្រួញចិញ្ចើមនឹកឃើញអ្វីម្យ៉ាង ក៏សួរថា ៖

- ហេតុអ្វីពូចិត្តល្អម្ល៉េះ អោយលុយខ្ញុំកាន់ដល់ទៅមួយរយដុល្លារ? មិនខ្លាចខ្ញុំយកហើយរត់បាត់ទេហ៍?

- អឺណ៎! ទៅគិតអីច្រើនម៉េះ? នែ៎ អញទុកចិត្តមីនាងឯង ឆាប់ទៅហៅមនុស្សអោយមកជួយយើងភ្លាមមក!

- ហើយពូឯងមិនមានទូរសព្ទ័ដៃហៅជំនួយទេហ៍ បានជា...?

- ចឹក៏មិនមាន... តែអញហៅគេម៉ាសន្ធុះហើយមិនទាន់ឃើញមានអាណាគេអើតក្បាលមកសោះ ។

ធិតានោះក៏លាតប្រាក់ឡើងយកមកមើល ហើយយក មកឈ្លី... ឈ្លីហើយជ្រលក់ទឹកប្រឡាយទៀត ។

- នែ៎ មីនាង! យកលុយអញទៅធ្វើអីហ្នឹង?

- ពិសោធន៍មើលក្រែងដុល្លារក្លែងក្លាយ ។

- គឺវាមិនក្លែងក្លាយទេ ពិសោធន៍ធ្វើអី?

រំពេចនោះ នាងលើកក្រដាសបញ្ជាំងទៅមេឃ ស្រាប់តែឈ្លីវា ហើយគប់ចំទ្រូងបុរសចំណាស់នោះផាច់ ព្រមទាំងស្រដីថា ៖

- លុយក្លែងក្លាយអញ្ចឹងតើហ៍ បានជាចិត្តល្អម្ល៉េះ? ពូបោកខ្ញុំមិន



បានទេ! ហ៊ឹះ! ព្រោះតែពូមានចិត្តទុច្ចរិតអញ្ចឹងទេនឹង ទើបទេវតាដាក់ទោសអោយធ្លាក់ប្រឡាយថ្ងៃនេះ ដោយគ្មាននរណាម្នាក់មានចិត្តមកជួយសោះ!!

ថាហើយ នាងក៏លុយទឹកគ្រាំៗត្រឡប់ទៅវិញ ។

- នែ៎ មីនាង ឈប់សិន! អញសាកចិត្តឯងលេងតើហ៍ ។ ត្រឡប់មកវិញអ៊ើយ! នេះ ចាំអញអោយអាលុយមែនទែន ។

ម្តងនេះ មាណវីត្រឡប់មកវិញ តែមិនព្រមយកលុយទេ បែរជាចង្អុលមុខបុរសនោះទៅវិញ ៖

- នែ៎ពូ! បើសិនជានិយាយអោយពិរោះជាងនេះបន្តិច ខ្ញុំនឹងទៅរកគេជួយលីពូដាក់ដីគោក ដោយមិនគិតថ្លៃទឹកតែ ។ តែបើពូស្រដីអញឯង ដូចពួកអាបង់ធំបង់តូចនោះ ពូឯងដេកចាំឡានប៉ូលីសគេមកសង្គ្រោះទៅ ។ ទីនេះ ញាតិជិតខាងគេរវល់ចេញទៅរកស៊ីអស់ហើយ គ្មាននរណាគេទំនេរមកជួយពូឯងទេ ។ បើសំបូរលុយណាស់ លើកក្រោយជួលតែកុងឡានមួយឲ្យជួយបរទៅ កុំបរខ្លួនឯងទៀត ក្រែងដល់ពេលមានអាសន្នលើកក្រោយ មានតែកុងបង្អោបកពូឯងដាក់ដីគោកវិញ ដើម្បីកុំអោយប្រឡាក់ជើងផង ។

- យី! ធ្វើឫកគ្រាន់បើមិនព្រមទទួលលុយផងហ្ន៎ស? ក្រមែនតែវាយឫកណាស់ នាងឯងនេះ ។

បុរសនោះរអ៊ូ តែម្តងនេះ មិនហ៊ានរអ៊ូរទាំងដូចមុនទេ ។ គាត់អង្គុយអេះក្បាលសម្លឹងមុខធិតាមួយស្របក់ ក៏និយាយថា ៖

- នែ៎ មីនាង! អញនិយាយលេងទេអ៊ើយ! ម៉ោះ! ជួយអញបន្តិចសិនមក៎!!

កាលបើឮដូច្នោះ ធិតាក៏តបវិញ ៖

- គិតម៉ត់ចត់មែនទែនហើយហ្ន៎ស ពូ?

បុរសនោះក៏ឯក២០ដុល្លារហុចអោយ ៖

- នេះយក២០ដុល្លារទៅ ហើយលីអញដាក់ដីគោកបន្តិចមក!

- ពុទ្ធោ ? អោយខ្ញុំហ្នឹង លីពូដាក់ដីគោក ?

- អើហ៍!

មាណវីបើកភ្នែកធំៗ មួយស្របក់មកក៏សើចខឹកៗតែម្តង ៖

- លីក៏លី... តែសុំប្រាំសន្លឹកបានទេ ?

- ថ្លៃម៉េះវ៉ុយ! ស្រីការ៉ាអូខេ អោយតែ១០ដុល្លារ បំរើដល់មួយយប់ឯណោះ ។ នេះគ្រាន់តែលីអញប្អូនឯប់ជំហាន ទារដល់ទៅមួយរយដុល្លារ ?

- នោះស្រីការ៉ាអូខេ! នេះស្រីលក់ផ្លែឈើ! វាខុសគ្នាណាំពូ! ម៉េចអោយឬមិនអោយ ?

ស្រាប់តែបុរសនោះញញឹម ហើយឯកហុចអោយនារីភ្លាម ថែមទាំងញាក់ចិញ្ចើមព្រើតៗ ទំនងសប្បាយចិត្តដែលបានស្រីក្មេងឲ្យគាត់អោបកពីក្រោយ ដើម្បីឆ្លងទឹក ។ មាណវីយើងទទួលលុយហើយក៏លើកយកពិនិត្យមើលថាជាលុយពិតប្រាកដ ហើយក៏រត់ទៅយកបាវមួយពីក្រោយកង់មកទ្រាប់ខ្នង មុននឹងអោយបុរសចាស់នោះឡើងទំបង្អោប់កលើខ្នងរបស់នាង ។

- នែ៎! យកបាវមកទ្រាប់ខ្នងធ្វើអី ? (បុរសចំណាស់សួរ)

- គឺ.. ការពារកុំអោយឆ្លងរោគ ។

- តែអញគ្មានរោគឆ្លងទេ វ៉ើយ!

- ពូមិនមាន តែខ្ញុំមាន!

- អូហ៍ ហើយមីនាងឯងកើតរោគអី ?

- កើតអេដស៍នោះអី!

- ងាប់បាត់! ឯងកើតរោគអេដស៍ ម៉េចមិនប្រាប់អញមុន ?



- ហើយ ចុះម៉េចពូឯងមិនសួរ ?

- ហ៊ឺះ! នែ៎ អោយលុយអញមក... អញទុកពឹងអ្នកផ្សេងវិញ ។

- យី! ពូចាស់នេះបោកក្មេងតើហ៎!

- នរណាថា ? ឯងតើហ៎ដែលបោកអញ!

- គឺពូឯងហ្នឹង មិនធ្វើតាមសន្យា!

- ព្រោះឯងកើតអេដស៍ មិនប្រាប់អញមុន ។

- យើងមិនបានកុងត្រាឯណាថា ខ្ញុំកើតអេដស៍ បង្អោបកពូឯងមិនបាន ? គ្រាន់តែថាអោយនាំទៅដាក់ដីគោកតែប៉ុនហ្នឹងឯង ។

បុរសនោះនិយាយមិនឈ្នះ ក៏បាត់មាត់ ។ រំពេចនោះ យុវជនជំទង់ដែលដើរកាត់ទីនេះមុននឹងបន្តិច ក៏មកដល់ ។ នារីក្រឡេកក៏ស្រែកហៅ ៖

- រក្សា! មកនេះជួយបងម៉ាភ្លែត!

- មិនជួយទេ (រក្សាឆ្លើយ) ទាល់តែមានថ្លៃកម្លាំងបាយ ។

- អឺ! ចាំដល់ផ្ទះ បងអោយ តែពេលនេះ ជួយបន្តិចសិនមក៍ ។

រក្សាបែរសម្លឹងមុខបងស្រី ហើយសម្លឹងបុរសនោះ តែក៏មិនប្រកែកអ្វីដែរ ។ នរ:ក៏ដើរលុយទឹកមកអោបកបុរសចំណាស់ចេញពីឡានទៅដាក់នៅដីគោក ។ គ្រាន់តែទំលាក់ខ្លួនដល់ដីភ្លាម បុរសនោះក៏យកដៃរឹតដើមទ្រូង ហើយស្រដីថា ៖

- វ៉ើយ ធូរពោះបន្តិច ដោយមិនបានឆ្លងអេដស៍!

- ឆ្លងអេដស៍រឿងអីទៅ ពូ ? (រក្សាសួរ)

- អើហ៍ មីនាងខាងនេះវាកើតអេដស៍ បានជាអញមិនអោយវាឱបកទៅដាក់លើគោក ជួនឯងមកដល់ ក៏បានឯងជួយអញផុតគ្រោះ ។

- ហើយចុះនរណាថាពូឯងរួចខ្លួន ?

- ហ្អាស ថាម៉េច ? នែ៎! កុំប្រាប់ណាំ ថាឯងក៏កើតអេដស៍ដែរ ?

- ចុះនរណាគេប្រាប់ពូ ថាអត់ ? ឪពុកខ្ញុំទើបតែស្លាប់ដោយសារអេដស៍កាលពីពីរឆ្នាំមុន ហើយម្តាយខ្ញុំស្លាប់ឆ្នាំទៅមិញជាមួយកូនប្រុសម្នាក់ ។

រីឯកូនៗនៅសល់កំពុងតម្រង់ជួរទៅតាមពីក្រោយហើយ...

- អូហ៍ ពុទ្ធោពុទ្ធំ! ងាប់អញបាត់...! អាលីងឆេង!!

តែពីរនាក់បងប្អូននោះមិនខ្វល់ទេ បែរជាកៀកគ្នាដើរចេញទៅ ទុកឲ្យបុរសនោះឈរអេះក្បាលតែម្នាក់ឯងយ៉ាងញាប់ញ័រ ។ រំពេចនោះ មានរថយន្តមួយទៀតបរនាំបុរសពីរបីនាក់មកដល់ ។ បុរសសូហ្វ័រឡានបើកទ្វារឡានចុះ មកទទួលបុរសចំណាស់ម្នាក់នោះចេញទៅ ។ ឯបុរសដទៃទៀត ក៏រៀបចំយកឡានមួយទៀតមកសណ្តោងអូសឡៃនគ្រូសរ៍ចេញពីប្រឡាយស្នាមភ្លោះ ។

តាមផ្លូវ រក្សាដើរកង់របស់បងស្រី ដើរដៃកគ្នាពីនាក់នាងត្រឡប់ចូលផ្ទះដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មានឡើយ ។

- បងរាសី! កៀបតាចាស់ម្នាក់នោះបានប៉ុន្មានដែរ ? មើលទៅមុខគាត់ ស្ងិតងល់ស្ងួរហើយ បងអើយ...!

- ស្ងិតយ៉ាងណា ក៏រាសីបូតទាល់តែបានខ្លះហ្នឹង ។ ពួកអ្នកមានឫកពាអន់ៗបែបហ្នឹង ច្បាស់ពួករកស៊ីផ្លូវកាត់មិនខានឡើយ ។

បន្តិចមក គេក៏មកដល់លំនៅតូចមួយ នៅក្នុងដីចំការដំណាំតូចមួយតាមងងផ្លូវ ។ នោះគ្រាន់តែជាកូនផ្ទះឈើតូចមួយ សង់ខ្ពស់ពីដីប្រហែលមួយម៉ែត្រ ។ ភ្លាមនោះ ស្រាប់តែពួកគេភ្ញាក់ព្រើតព្រោះឃើញរថយន្តថ្មីស្រឡាងមួយ ដែលដឹកបុរសចំណាស់អំបាញមិញនោះ បានមកសំចតនៅមុខផ្ទះរបស់គេ ដោយមានសូហ្វ័រឡានឈរចាំផង ។ អ្នកទាំងពីរបែរមើលមុខគ្នាធ្វើភាំង ។ លុះគេនាំគ្នាស្ទុះឡើងលើផ្ទះ ក៏ប្រទះឃើញបុរសចំណាស់ដដែលនោះនៅអង្គុយ



លើកន្ទេលក្រហមមួយចំកណ្តាលផ្ទះ ព្រមទាំងមាននារីសោភាម្នាក់អាយុប្រហែល១៦ឆ្នាំ កំពុងបំរើទឹកភេសជ្ជៈជូនគាត់ផង ។

- រស្មី ? ភ្ញៀវម្នាក់នេះជានរណា ?

រាសីសួររស្មីជាប្អូនស្រីរបស់នាង ដែលកំពុងលើកចាសភេសជ្ជៈនោះ ។ កាលបើឃើញបងស្រីបងប្រុសដើរចូលមក នាងក៏ញញឹមហើយឆ្លើយថា ៖

- បងរាសី! នេះថៅកែ ឌាំង! គាត់ជាថៅកែធំម្នាក់នៅភ្នំពេញមានសាខាជំនួញតាមខេត្តច្រើនទៀតរួមទាំងបាត់ដំបងផង ។ គាត់ចិត្តល្អណាស់ ហើយបានសុំខ្ញុំធ្វើកូនធម៌ទៀតផង ។

រាសីបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ។ នាងមិនរវល់នឹងគួរសមជាមួយបុរសចំណាស់ម្នាក់នោះទេ បែរជាមកសួរប្អូនស្រីថា ៖

- ហើយចុះឯងទៅស្គាល់គេពីអង្កាល់ ?

- គឺ... កាល... ពួកម៉ាកខ្ញុំ គេណែនាំអោយស្គាល់...

ស្រាប់តែបុរសនោះសើចក្អឹកៗហើយឆ្លើយជំនួសថា ៖

- ម៉េចក៏រស្មីមិនប្រាប់ទៅថា នាងបានជួបប៉ា ពេលទៅសុំការធ្វើនៅហាងការ៉ាអូខេ ?

រាសីរិតតែភ្ញាក់ផ្អើលឡើង រួចឧទានថា ៖

- រស្មី! បងអោយប្អូនទៅរៀន ប៉ុន្តែហេតុអ្វីបែរជាទៅរកការធ្វើនៅហាងការ៉ាអូខេទៅវិញអញ្ចឹង ?

- គឺខ្ញុំរៀនមិនចូលនោះអី ? រៀនធ្វើអី កាលបើរៀនចប់ ក៏ប្រឡងមិនជាប់ដដែល បើគ្មានលុយស៊កហោប៉ៅគេ ?

រាសីខកចិត្តណាស់ ក៏ច្រានទ្រូងប្អូនស្រីសឹងផ្ងាកក្រោយ ៖

- ហើយអារបររកស៊ីជាស្រីការ៉ាអូខេនោះវាមានអនាគតអីដែរទៅ ?

- មានឬមិនមាន ក៏គង់រកលុយបាន មានការសប្បាយបំភ្លេចទុក្ខ

ម៉ាគ្រាៗ គ្រាន់បើជាងជីវិតសព្វថ្ងៃដែលខំរកស៊ីសុចរិតសព្វយ៉ាង តែក៏នៅតែក្រីក្រខ្វះមុខខ្វះក្រោយ...មិនឃើញចំរុងចំរើនឯណា ?

- តែសំបុកដែលឯងដើរចូលនោះជារង្វង់ដែលនាំឯងធ្លាក់អវិចី បើមិនស្លាប់ដោយញៀនស្រា ញៀនថ្នាំញៀន ក៏នឹងស្លាប់ដោយរោគអេដស៍មុនអាយុ! (រាសីគំហក)

- ចុះម៉ែយើងវិញនោះ ? ម៉ែមិនដែលចូលកន្លែងអស់ហ្នឹងផង ហេតុអ្វីក៏កើតរោគអេដស៍ ស្លាប់នឹងគេដែរ ?

- គឺមកពីឪពុកយើងនោះអី! ឪពុករបស់យើងបានប្រព្រឹត្តបាបកម្ម ហើយក៏នាំជម្ងឺទម្លាក់ដល់ម៉ាក់ រួចឥឡូវនេះទៀត ចរិតវង្វេងរបស់គាត់ក៏បានជ្រួតជ្រាបដាំជាប់នឹងខ្លួនរបស់ឯងជាកូនទៀតហើយ ឯងឃើញហើយនៅ ?

- តែខ្ញុំមិនខ្វល់! បងចង់រស់អាយុវែងនៅឯណាក៏ទៅរស់ទៅ! ខ្ញុំនឹងទៅរស់នៅដោយខ្លួនឯង មិនចាំបាច់ចាំបងធ្វើឫកជាឈឺឆ្អាលចំពោះជីវិតរបស់ខ្ញុំតទៅទៀតទេ ។ ការដែលត្រឹមផ្គត់ផ្គង់ត្រឹមបាយកកស្ករផែនបែបនេះ ខ្ញុំមិនត្រេកត្រអាលឡើយ ហើយកុំសង្ឃឹមថាអាចធ្វើអោយខ្ញុំរំភើបចិត្តចំពោះទង្វើដ៏ល្ងង់របស់បង ដែលមិនចេះរកលុយ ចេះត្រឹមតែលក់ផ្លែឈើនោះ! ជីវិតកណ្តាច់កណ្តោចបែបនេះ គ្មានតម្លៃគួរឲ្យខ្ញុំមានមោទនភាពជាមួយទេ... វេទនាណាស់!

ថាហើយ នាងក៏លូកចាប់ដៃបុរសចំណាស់នោះដើរដើរចេញទៅក្រៅយ៉ាងលឿន ៖

- តោះប៉ា! យកខ្ញុំចេញពីទីនេះភ្លាមទៅ! ខ្ញុំមិនចង់នៅឃើញមុខមនុស្សដែលពាក់មុខបិសាចដាក់ខ្ញុំដូច្នេះតទៅទៀតឡើយ ។

រស្មីងាកមកសម្លក់បងស្រីរបស់ខ្លួន ហើយក៏អូសដៃថៅកែខាំងនោះចេញទៅ ធ្វើអោយរស្មីខកចិត្ត ស្រឡាំងកាំងនិយាយលែងរួច



តែម្តង ។ នាងក៏រត់យ៉ាងលឿនទៅអូសដៃប្អូនស្រីមកវិញ ៖

- អត់ទេ រស្មី! បងមិនអោយប្អូនទៅទេ! ទៅមិនបានទេ!

- លែងខ្ញុំ បងរាសី! បើបងគ្រាន់បើពិតមែន បងបង្ហាញខ្ញុំមកថាជីវិតបងនឹងគ្រាន់បើជាងរូបខ្ញុំ នៅរវាងពីរបីឆ្នាំទៀត ចាំមើលថាតើអ្នកលក់ផ្លែឈើដូចបង និងនារីការ៉ាអូខេដូចខ្ញុំនេះ តើនរណាមានជីវិតប្រសើរជាងនរណា!

ថាហើយ រស្មីរលាស់ដៃពីបងស្រី ហក់ឡើងរថយន្តដ៏ស្រឡាងជាមួយថៅកែខាំងនោះយ៉ាងរហ័ស ។ រថយន្តក៏បរចេញទៅ... ទុកអោយរាសីរត់តាមពីក្រោយស្រែកយំហៅប្អូនល្វើយៗ ៖

- អត់ទេ! រស្មី! កុំទៅអី! ត្រឡប់មកផ្ទះវិញអូន! កុំចាញ់បោកគេណា៎ រស្មី!.... រស្មី!

អនិច្ចា! រថយន្តបរចេញទៅឆ្ងាយហើយ នៅសល់តែដីហុយទ្រលោមពីក្រោយប៉ុណ្ណោះ ។ រាសីទុចដំណើរដ៏ក់ ព្រោះដឹងថានាងមិនអាចរត់ទាន់រថយន្តឡើយ ។ រំពេចនោះ រាសីដាក់ភ្នែកទៅម្ខាងឃើញបុរសម្នាក់ពាក់មួយកន្តិប ពាក់អាវពណ៌ប្រផេះ កំពុងជួយអូសឡានរបស់បុរសចាស់នោះឡើងដល់លើគោក ដោយមានជំនួយពីរថយន្តធំមួយទៀតនិងកម្មករពីរបីនាក់ ។ បុរសនោះបានចោលកន្ទុយភ្នែកមើលនាងភ្លៀកៗ ។ ធិតាចាប់ភ្លឹកភ្លាម ហើយក៏គំហកឡើងទៅមាណពនោះ ទាំងទឹកភ្នែកពេញមុខ ថា ៖

- នែ៎! លួចសម្លឹងមើលស្អី ? សប្បាយចិត្តណាស់មែនទេ ដែលថៅកែរបស់អ្នក ដើរទាក់ក្មេងស្រីដាក់ហាងការ៉ាអូខេដូច្នេះ ?

បុរសនោះនៅស្ងៀមមិនតបទេ តែបែរទាញមួកបន្ទាបលិចមុខថែមទៀតរួចក៏ឈ្ងោកមុខគេចចេញ ។ រាសីសម្លក់បុរសនោះហើយក៏សម្លក់បុរសទាំងអស់ ដែលកំពុងរៀបរថយន្តសណ្តោងអូសឡាន

ឡើងពីភក់មក រួចហើយក៏ស្រែកអោយពួកគេថា ៖

- ឲ្យអ្នកទាំងអស់សើចយំខ្ញុំសិនចុះ! ថ្ងៃណាមួយរាសីខ្ញុំអណ្តែតខ្ពស់ដល់មេឃ ខ្ញុំនឹងអូសអ្នកចេញពីការបំរើជនពាលឧក្រិដ្ឋមុខខ្លាញ់នេះឲ្យអស់ មិនឲ្យស៊ីប្រាក់ខែពួកទុច្ចរិតតទៅទៀតឡើយ ។

រាសីខាំធ្មេញក្រឹតៗ យកដៃជូតទឹកភ្នែក រួចនិយាយបន្តថា ៖

- ថ្ងៃណាមួយ កំទេចអំបែងដូចជាយើងនឹងអណ្តែតឡើងផុតផ្ទៃទឹកអោយអ្នករាល់គ្នាដែលមានបេះដូងឧក្រិដ្ឋទាំងឡាយ លោះព្រលឹងមិនខាន! ចាំតែមើលចុះ!

ថាហើយ រាសីក៏បែរដើរត្រឡប់ក្រោយទៅផ្ទះវិញ ទុកអោយបុរសមួយរូបនោះលួចឈរគន់មើលនាង យ៉ាងភ្លន់ភ្លឹកពីក្រោយដោយកិរិយាស្ងាត់ស្ងៀមតែម្នាក់ឯង ។

- បងរាសី... (រក្សាដើរមកដល់ជិត ហៅបងស្រីតិចៗ)

- បងមិននឹកស្មានសោះ រក្សា... ថាប្អូនស្រីរបស់បងហ៊ានប្រមាថមាក់ងាយទឹកចិត្តបងស្រីរបស់គេដល់ម្លឹង ?... (រាសីយកដៃផ្ដិតទឹកភ្នែកដែលកំពុងតែស្រក់ចុះមកលើផ្ទៃមុខរបស់នាងជាថ្មី)

- រស្មីគេមិនយល់មែន... តែរក្សាយល់ចិត្តបងណាស់!

ឮប្រយោគនេះភ្លាម រាសីក៏ងើបមុខឡើង ៖

- បងអរគុណណាស់ រក្សា! ទោះបីជាយ៉ាងណា បងក៏នៅតែបារម្ភពីសុខទុក្ខរបស់រស្មីជានិច្ច ព្រោះគេនៅក្មេង ពិតជាហក់លោតតាមល្បិចចាស់ទុច្ចរិតមិនទាន់ឡើយ ។

- តែរស្មីគេបានជ្រើសរើសយកផ្លូវជីវិតបែបនោះ រួចទៅហើយដូច្នេះនាងត្រូវតែហ៊ានទទួលយកនូវលទ្ធផលចុងក្រោយ របស់ជីវិតបែបនោះ ដោយមិនអាចប្រែកែកបានទេ ។

បន្តិចមក រាសីកាន់ដៃប្អូនប្រុសដើរចូលទៅក្នុងផ្ទះវិញ វែករាំង



ននចូលទៅក្នុងបន្ទប់ ក៏ប្រទះនឹងកុមារជំទង់មួយអាយុប្រហែល ១០ឆ្នាំ រាងស្គាំងស្គមស្លេកស្លាំង កំពុងតែគេងឈឺលើកន្ទេល...

- រតនា! ប្អូនបានធូរស្រាលគ្រាន់បើខ្លះ ថ្ងៃនេះ ?

នោះគឺជារតនាជាប្អូនបន្ទាប់ពៅ ។ ការពិត រាសីមានបងប្អូនដល់ទៅប្រាំមួយនាក់ ។ ឪពុករបស់នាងបានស្លាប់ទៅដោយជំងឺអេដស៍ហើយបានចម្លងមកដល់ម្ដាយរបស់នាង ។ ចំណែកប្អូនពៅវិញបានឈឺស្លាប់ នៅអាទិត្យជាមួយគ្នានឹងម្ដាយរបស់នាងដែរ ។ តាមការពិត គ្មាននរណាដឹងថា ប្អូនពៅរបស់នាងស្លាប់ព្រោះអេដស៍ ឫជំងឺអ្វីផ្សេងទៀតឡើយ ត្បិតគេស្លាប់ទាន់ហាន់ពេក ។ ម្យ៉ាងទៀតកាលនោះ ពេលប្អូនដេកឈឺ រាសីគ្មានលុយយកគេទៅពេទ្យពិនិត្យជម្ងឺរបស់ប្អូនអោយបានត្រឹមត្រូវផង ។ មិនទាន់បានប៉ុន្មានផងរតនាជាប្អូនបន្ទាប់ពៅ ក៏ធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ទៀត ។ ឯគ្រួសាររបស់រាសីដែលធ្លាប់ជាមនុស្សមានទ្រព្យធនមធ្យមមួយ ក៏បានក្លាយធ្លាក់ខ្លួនជាជនទុរគត ព្រោះត្រូវលក់ដីលក់ផ្ទះរកលុយព្យាបាលជំងឺរបស់ឪពុកម្ដាយនាង ។ សព្វថ្ងៃនេះ គ្មាននរណាគេទៅមករាប់រកក្រុមគ្រួសាររបស់រាសីឡើយ ព្រោះគេខ្លាចត្រូវស្លាប់ដោយការឆ្លងមេរោគអេដស៍ពីគ្រួសារនេះ ។ កាលពីមុន គ្រួសារគេរស់នៅឯផ្សារណាត់ ។ បន្ទាប់ពីលក់ផ្ទះសងបំណុលគេមក រាសីក៏នាំប្អូនរត់មកនៅផ្ទះចាស់របស់គេ នៅម្ដុំព្រៃកូនខ្លា លាក់ខ្លួនពួនអាត្មា មិនអោយមានគេស្គាល់ថា សមាជិកគ្រួសាររបស់នាង មានជំងឺអេដស៍ទេ ។ រាសីក៏បានឈប់រៀនពីវិទ្យាល័យមុនីវង្ស ហើយប្រកបរបរដួញផ្លែឈើពីចំការយកទៅបោះនៅផ្សារផង ដូនធ្វើនំលក់ផង ដើម្បីចិញ្ចឹមប្អូនៗ ។ ឯរក្សាវិញត្រូវប្រឡងបញ្ចប់មធ្យមសិក្សាឆ្នាំនេះ ។ ស្ដាយតែរស្មីទេដែលបែកគំនិតផ្ដេសផ្ដាសតាំងពីម្ដាយនាងស្លាប់ទៅព្រោះ

រស្មីមិនអាចទ្រាំទ្រទទួលជីវិតដ៏ក្រីក្រអត្តខាត់បាន ។ រដ្ឋាជាកូនទី៤ អាយុ១៨ឆ្នាំ ចេញដើរបាត់ៗ ឃើញៗ តាមតែដំណើរ ជួនមកផ្ទះ ជួនបាត់ប្អូនដប់ថ្ងៃទើបអើតមុខមកផ្ទះម្តង ។ គេក៏គេចសាលាមិនខុសពីរស្មីបងស្រីរបស់គេឡើយ ។ សល់តែរតនាជាប្អូនពៅ កំពុងចាប់មានជំងឺទៀតហើយ... គ្រប់គ្នាគិតថា គេប្រហែលជាកំពុងទទួលជាការទន្ទ្រានរបស់ជំងឺអេដស៍បន្តពីឪពុកម្តាយហើយ ។

ឃើញរាសីនិងរក្សាដើរចូលមក រតនាបែរនិយាយខ្សាវៗដាក់បងស្រីនិងបងប្រុសរបស់ខ្លួន ៖

- ខ្ញុំជិតស្លាប់ហើយមែនទេ បងរាសី បងរក្សា ? ខ្ញុំខ្លាចណាស់... ខ្ញុំមិនចង់ស្លាប់ទេ...ថ្ងៃនេះ... ខ្ញុំហេងហោងក្នុងខ្លួនណាស់...

រតនាស្រដីផងរលីងរលោងទឹកភ្នែកផង ។ រាសីដាក់ខ្លួនអង្គុយជិតប្អូនហើយយកដៃអង្អែលក្បាលកុមារដោយក្តីអាណិតអាសូរ ៖

- រតនាមិនទៅណាចោលបងទេ! ប្អូនគ្រាន់តែគ្រុនក្តៅប៉ុណ្ណោះ ។ ប្អូនញ៉ាំថ្នាំសំរាកតែពីរបីថ្ងៃទៀតជាវិញហើយ ។
- បងនិយាយពិត ឬក៏គ្រាន់តែលួងចិត្តប្អូនទេ បងរាសី ? ខ្ញុំពិតជាមិនទាន់ចង់ស្លាប់ទៅតាមប៉ាម៉ាក់និងប្អូនពៅទេ ។ ខ្ញុំខ្លាច...

រាសីលើកប្អូនមកអោបយ៉ាងណែន ៖

- ប្អូនកុំខ្លាចអី... បន្តិចទៀតប្អូនជាវិញហើយណា៎...!

រំពេចនោះ រតនាក៏ត្រឡប់ភ្នែកឡើងដង្ហក់ខ្យល់ ៖

- បង... រាសី... បង...រក្សា....

ស្រាប់តែនាយធ្វើភ្នែកខៀវទៅៗ រួចហើយក៏បាក់ករងៀកទៅក្រោយដកចង្កមាន់មួយរំពេច ។

- រតនា! ប្អូនសម្លាញ់របស់បង..!

រាសីទ្រហោរយំផង អោបប្អូនផង ទាំងក្តីរន្ធត់តក់ស្លុតក្នុងចិត្ត



ឥតឧបមា ។ រក្សាក៏ទប់ចិត្តមិនបានក៏ស្រក់ទឹកភ្នែកតាមដែរ... នេះហើយឬវិបត្តិនៃជំងឺអេដស៍ ? ឪពុកភ្លើតភ្លើនទៅសប្បាយនៅក្រៅដោយមិនគិត តែអ្នកទទួលរងគ្រោះវិញនោះ បែរក្លាយមកជាប្រពន្ធកូនដែលមិនបានដឹងនូវអំពើឧក្រិដ្ឋរបស់ឪពុកនោះទៅវិញ ?

រាសីបីសពប្អូននៅក្នុងដៃជ្រួញចិញ្ចើមគិតមិនអស់មិនហើយ ។ មើលចុះ! គេនៅក្មេងណាស់! គេទើបតែមានអាយុ១០ឆ្នាំ មានវ័យស្រស់ថ្លាដែលគួរណាស់តែបានទទួលអនាគតល្អ តែបែរជាមករលត់សង្ខារទាំងក្មេងដោយសារភាពរាយមាយរបស់ឪពុកគេ... ឱ! លោកឪពុកអើយ! បើសិនមានឱកាសនៅគិតបាន តើលោកគួរគិតយ៉ាងណាវិញ ដើម្បីអោយកូនមានអនាគតឆ្ងាយ ជាជាងឲ្យគ្នាមកបញ្ចប់សង្ខារដោយឥតន័យយ៉ាងនេះ ? តើលោកឪពុកគួរក្លាយខ្លួនជាឃាតករសម្លាប់កូនប្រពន្ធតាមវិធីបែបនេះទេ ?.... តើឯណាទៅក្តីស្រឡាញ់ដែលលោកឪពុកគួរផ្តល់ចំពោះកូនប្រពន្ធ ? លោកឪពុកជាអ្នកមានគុណយ៉ាងធ្ងន់ចំពោះកូន... ប៉ុន្តែ រឿងដែលលោកឪពុកធ្វើឲ្យ កូនរបស់លោកស្លាប់ទៅដោយការប្រព្រឹត្តឧក្រិដ្ឋរបស់លោកឪពុករបៀបនេះ តើគួរឲ្យកូនគិតថា លោកឪពុកជាអ្នកមានគុណ ឬក៏ជាឃាតករសម្លាប់កូន សម្លាប់ប្រពន្ធរបស់ខ្លួន ? តើគុណនិងទោសអាចសងគ្នារួចទេ ចំពោះករណីខាងលើនេះ ?

នៅចំពោះមុខចេតិយមួយនៅវត្តកំផែង...

រក្សានិងរាសីឈរស្មឹងស្មាធយ៉ាងយូរ ។ បន្ទាប់មក រាសីក៏ស្រដីថា ៖

- ម៉ាក់! រតនា! ពៅ! សូមអោយវិញ្ញាណក្ខន្ធ័របស់អ្នកទាំងបីបានទៅដល់ស្ថានសុគតិភព កុំបីខាន ។

រក្សាភ្ញាក់ព្រើត នឹកចម្លែកក្នុងចិត្តដែលគេមិនបានឮរាសីហៅ

រកវិញ្ញាណក្ខន្ធ័របស់ឪពុកសោះ ។ ប៉ុន្តែ គេមិនស្រដីអ្វីទេ ។ គេនៅតែស្ងៀមតាមទម្លាប់របស់គេដែលគោរពបងស្រីបំផុត ។

បន្តិចមក រក្សាក៏ឡើងធាក់កង់ឌុបបងស្រីត្រឡប់ទៅផ្ទះវិញ ។ ស្រាប់តែគេប្រទះនឹងក្មេងជំទង់បីបួននាក់កំពុងវាយគ្នានៅក្បែររនងទង់វត្ត កណ្តាលទីធ្លាស្ងួនច្បារដែលមានរូបចម្លាក់ស្អាតៗជាច្រើន ។

- នែ៎! ពួកឯងឈប់វាយគ្នា! ទីនេះជាវត្តអារាមមិនមែនសង្វៀនប្រដាល់សេរីទេ ។

រក្សាស្រែកឃាត់ ។ ស្រាប់តែ... ខ្ទាប់ៗ ក្មេងម្នាក់យារដាវគ្រវីកាប់ឆិតៗក្បាលរក្សា ។ យុវជនយើងហក់ចុះពីកង់ គ្រវីខ្លួនខ្វាល់គេចផ្លែដាវសាមូរ៉ៃ ហើយព្រលែងជើងព្រលែងដៃយ៉ាងរស់ក្បាច់ព្រលំក្មេងៗទាំងនេះដួលត្នោលៗ ។ រាសីឃើញហើយក៏ស្ទុះហក់រីងទៅក្របួចក្មេងម្នាក់ក្នុងចំណោមបួននាក់នោះឡើង ៖

- គឺឯងទេ រដ្ឋា ? ឥឡូវធ្លាក់ខ្លួនដល់ថ្នាក់នេះហើយ ប្អូនសម្លាញ់ ? ឥឡូវនេះ ឯងជក់ថ្នាំញៀន រហូតក្លាយជាអ្នកលេងកាប់ដាវផងមែនទេ ?

មែនហើយ នោះគឺរដ្ឋា ប្អូនប្រុសរបស់អ្នកទាំងពីរ ។ គ្រាន់តែឃើញមុខបងប្រុស បងស្រីភ្លាម គេក៏ធ្វើមុខស្លេកតែម្តង ។ រំពេចនោះ ក្មេងពីរនាក់បានដាក់មេជាយទៅបាត់ស្រមោល សល់តែក្មេងប្រុសម្នាក់ដែលរក្សាចាប់បាន ដោះយកអាវមកចងដៃ ។ បន្តិចមកព្រះសង្ឃព្រមទាំងអាចារ្យវត្តនិងអ្នកស្រុកចំណុះជើងវត្ត ក៏បានមកដល់ ។ គេក៏ចាប់កុមារជំទង់ម្នាក់នោះចេញទៅ ។ ចំណែករដ្ឋាបានត្រូវបងប្រុសបងស្រីចាប់ប្រគល់អោយទៅព្រះគ្រូអធិការ ។

- លោកតា! តើអាចទទួលយកក្មេងមួយនេះ អោយជ្រកម្លប់ព្រះធម៌ផងបានទេ ? (រាសីក្រាបបង្គំសុំព្រះគ្រូចៅអធិការ)



- អត់ទេ! ខ្ញុំមិនចង់បួសទេ (រដ្ឋាស្រែកកាត់) ខ្ញុំមិនចូលចិត្តធ្វើខ្លួនជាលោកសង្ឃអត់បាយល្ងាចនោះទេ ។

- ឈប់មាត់! (រក្សាគំហកតិចៗ) ទីនេះជាវត្តអារាម ប្អូនត្រូវរៀបចំកិរិយាបថអោយសមរម្យបន្តិចផង ។

ភ្លាមនោះ ព្រះគ្រូមានដីការឡើងថា ៖

- នឹងអោយគេបួសតែម្តងនោះមិនបានទេ ព្រោះគេនៅមានជាតិញៀនក្នុងខ្លួនប្រាណគេនៅឡើយ តែលោកតាសុំបិណ្ឌបាតយកគេអោយនៅបំរើជាកូនសិស្សនៅទីនេះសិនចុះ ។

រាសីក្រាបបង្គំព្រះគ្រូ ៖

- អរគុណលោកតាណាស់ ដែលជួយយិតយោងសត្វលង់ទឹកដូចជារូបគេ ។ ចំពោះខ្ញុំករុណាដែលជាបងទាំងពីរនាក់ ពេលនេះ គ្មានសមត្ថភាពអ្វីនឹងជួយគេបានទេ មើលទៅមានតែពឹងលើព្រះគ្រូ ជាអ្នកតម្រែតម្រង់ហើយ ។

- មិនអីទេ! ទុកអោយលោកតាជួយទទួលខុសត្រូវចុះ ។

- អត់ទេ! ខ្ញុំចង់ទៅផ្ទះវិញ! ខ្ញុំមិនចង់នៅវត្តទេ (រដ្ឋាស្រែក)

ស្រាប់តែរាសីពោលឡើងថា ៖

- កុំប្រឹងភូតបងអី រដ្ឋា! ឯងឯណាដែលចង់ទៅផ្ទះ នៅផ្ទះជាមួយពួកយើង ? យើងបានចាប់ប្អូនមកផ្ទះច្រើនដងហើយ តែប្អូនបែរជារត់ពីផ្ទះរាល់លើក ។ លើកនេះ បងមិនយកឯងទៅផ្ទះទេ ព្រោះឯងបានវាយតប់គ្នា ធ្វើអោយខូចបែកបាក់ទ្រព្យសម្បត្តិរបស់វត្តអារាម ដូចនេះ ឯងត្រូវតែធ្វើការបំរើ ជាសំណងដល់ការខូចខាតទាំងនោះ ។ បើមិនសុខចិត្តទេ បងនឹងចាប់ប្អូនបញ្ជូនអោយអង្គការកែក្មេងញៀនគ្រឿងញៀនអោយគេអប់រំឯងហើយ ។ ឥឡូវជ្រើសរើសមួយទៅ តើឯងចង់យកផ្លូវមួយណា ?

ដោយទាល់ច្រក រន្ធាក៏ល្មោកមុខនៅស្ងៀម ។

ក្រោយពីប្រគល់ប្អូនប្រុសទៅលោកតាអធិការហើយ រក្សាក៏ឌុបបងស្រីត្រឡប់មកផ្ទះវិញ ។ យប់នោះ រាសីនៅអង្គុយសំកុកមាត់ជណ្តើរ អង្គុយមើលមេឃ មិនព្រមចូលគេងសោះ ។ រក្សាឃើញហើយក៏លូនចូលមកជិត ហើយនិយាយថា ៖

- បងរាសី! យប់ហើយណា៎! មិនចូលគេងទេ?
- បងមិនទាន់ងុយទេ រក្សា! ប្អូនចូលគេងមុនទៅ ។
- ប៉ុន្តែ បងក៏ត្រូវចូលគេងដែរ កុំអត់ងងុយច្រើនពេក តិចលោឈឺម្នាក់ទៀតទៅ ។
- ទោះជាបងប្រឹងគេង ក៏មិនលក់ដែររក្សា... ព្រោះបងកំពុងគិតពីថ្ងៃស្អែករបស់យើង...
- រស់តាមតែដំណើរសិនទៅបង! ទោះបីជាគិត ក៏យើងមិនអាចដោះស្រាយអ្វីបានដែរ មានតែឈានដើរទៅមុខបន្តទៅទៀតតែប៉ុណ្ណោះ ។
- រក្សានិយាយត្រូវហើយ! យើងត្រូវបោះជំហានទៅមុខ ប៉ុន្តែបងមិនដឹងថា ត្រូវបោះជំហានខាងណា ដើម្បីកុំឲ្យធ្លាក់ជ្រោះដូចជីវិតប៉ាម៉ាក់របស់យើង ។ រក្សានឹងប្រឡងបញ្ចប់ការសិក្សាឆ្នាំនេះ ហើយប្អូននឹងត្រូវបន្តការសិក្សាទៅមុខទៀត... តើបងត្រូវធ្វើការអ្វីដើម្បីយកប្រាក់មកបង់សាលាអោយរក្សា រួចជួយផ្គត់ផ្គង់នល់រន្ធាផង?

រក្សាញញឹមហើយស្រដីថា ៖

- ជំហានទីមួយនោះ គឺ បងនិងខ្ញុំត្រូវទៅរកពេទ្យជោះឈាមមើលហើយ ខ្លាចយើងមានចម្លងមេរោគអេដស៍ពីសមាជិកក្រុមគ្រួសាររបស់យើង ។
- បងថា យើងមិនបានឆ្លងអេដស៍ទេ ។ ប្អូនរបស់យើងពីរនាក់



ដែលស្លាប់ អាចស្លាប់មកពីជំងឺផ្សេងទៀតក៏បានដែរ មិនមែនឲ្យតែស្លាប់ ក៏សុទ្ធតែមកពីអេដស៍ទាំងអស់នោះទេ ។
- តែក៏វាអាចទៅរួចណា៎បង ព្រោះយើងរស់នៅជាមួយគ្នាជិតដិតអាចឆ្លងមេរោគតាមស្បែក ដែលមុតចំហមុខក៏មានដែរ ។
- អឺ! បងជឿតាមឯងចុះ ។ អញ្ចឹងយើងទៅរកពេទ្យជោះឈាមរួចហើយ យើងនឹកមកដេកគិតគ្នា ថាធ្វើដូចម្តេចទៀត ដើម្បីរកលុយបង់សាលាអោយឯងរៀន ។ បងចង់អោយរក្សារៀនបានឆ្ងាយកុំអោយដូចបងដែលត្រូវបង្ខំចិត្តលាសាលាទាំងក្មេង ដើម្បីមកថែទាំប៉ាម៉ាក់នោះឡើយ ។
- ប៉ុន្តែបងបានធ្វើល្អបំផុត ចំពោះក្រុមគ្រួសារយើងហើយ ។ បើកុំតែមានរូបបង មិនដឹងថា ពួកយើងរស់នៅយ៉ាងណាទេ ជាពិសេសតាំងពីប៉ាម៉ាក់គាត់ចែកស្ថានទៅ ។
- ហ៊ឹ! បងប្រឹងអស់សមត្ថភាពហើយ រក្សា តែបងនៅតែមិនអាចគ្រប់គ្រងប្អូនអោយបានល្អដូចចិត្តបងប៉ងប្រាថ្នាទេ ។ ប្អូនមិនឃើញទេ? ប្អូនយើងខ្លះប្រមាថសមត្ថភាពបងណាស់ដែលបងមិនអាចរកប្រាក់ផ្គត់ផ្គង់រូបគេអោយរស់នៅស្រណុកសុខស្រួលបាន... នេះគឺមកពីបងរៀនមិនចប់ ទើបបងគ្មានសមត្ថភាពអ្វីនឹងរកការងារធ្វើឲ្យប្រសើរជាងនេះបាន បានត្រឹមតែជាឈ្មួញលើកផ្លែឈើលើកបន្លែលក់ដុំនៅផ្សារ និងធ្វើនំ ធ្វើបង្អែមលក់ តាមដែលធ្វើបានតែប៉ុណ្ណោះ ។
- បងកុំពិបាកចិត្តអី! រក្សាក៏មានសាច់ដុំគួរសមដែរ អាចជួយជាដៃជើងបានខ្លះ មិនអោយបងនឿយតែម្នាក់ឯងនោះទេ ។

រាសីឮដូច្នោះ ក៏យកដៃអង្អែលស្មាប្អូនដែលអង្គុយទន្ទឹមនឹងនាងនៅមាត់ជណ្តើរផ្ទះ ហើយញញឹមឡើង ៖

- ពេលនេះ បងសប្បាយចិត្តវិញហើយ ដែលហោចណាស់ បងនៅមានប្អូនប្រុសយ៉ាងល្អម្នាក់ ដែលមិនបណ្តោយអោយបងស្រក់ទឹកភ្នែកអាសារឥតការ ។

- គឺមកពីយើងជាបងប្អូនដែលស្រឡាញ់គ្នាបំផុតនោះអី ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើង ដោយដួងចិត្តពោរពេញដោយក្តីសង្ឃឹមជាថ្មី ថ្វីបើក្នុងបេះដូងរបស់គេពោរពេញទៅដោយកង្វល់នឹកគិតទៅដល់រស្មី ប្អូនស្រីរបស់គេ ដែលរត់តាមបុរសចំណាស់កំពូលខិលនោះទៅ កាលពីប៉ុន្មានថ្ងៃមុន រួចហើយក៏បារម្ភដល់រដ្ឋា ដែលកំពុងតែញៀនគ្រឿងញៀន មិនដឹងថាលោកគ្រូអធិការអាចរំលត់ភាពញៀននិងមារយាទព្រហើនរាយមាយរបស់នាយបានដែរឬក៏យ៉ាងណា...

ទោះបីជាយ៉ាងណា គេមិនលះបង់សេចក្តីសង្ឃឹមរបស់គេទេ ហើយគេទាំងពីរបានស្រាក់ដៃសន្យាគ្នា ថានឹងពុះពារតទៅទៀត ដើម្បីដើរឆ្ពោះទៅរកអនាគតមួយដែលគ្រប់ៗគ្នាគិតថា គេទាំងពីរនាក់នោះពិតជាមិនអាចមានសមត្ថភាពដើរទៅដល់ឡើយ ក្នុងមួយជីវិតរបស់គេនេះ...

តើគេអាចធ្វើបានសំរេចដូចបំណងឬក៏យ៉ាងណា ?

00000000000000000000

00000

0



# វគ្គទីពីរ

# រាសីថ្មី

នៅភោជនីយដ្ឋានមនោរម្យមួយ លើផងផ្លូវទៅព្រែកលាប...

បុរសសង្ហាមួយរូបពាក់វ៉ែនតាខ្មៅដែលមានវ័យប្រមាណ៣០ឆ្នាំដើរចុះពីរថយន្តតែម្នាក់ឯង ដើរសំដៅចូលទៅក្នុង ដោយឫកពាឆ្មើងឆ្មៃ ។ រំពេចនោះ អ្នកបំរើបាននាំគេមកដល់តុដ៏ស្អាតមួយនៅលើរានហាលបែរទៅទន្លេ ឆ្ងាយពីវេទិកាចម្រៀងសម័យបន្តិច មិនសូវជាថ្លង់ក្នុងត្រចៀកទេ ។ មាណពមិនទាន់ទាំងដាក់ខ្លួនអង្គុយស្រួលបួលផង ស្រាប់តែស្រីៗឡង់សេមួយហ្វូងរត់ជាន់កែងជើងគ្នាយករូបស្រាបៀរមកហុចជូនបុរសសង្ហានោះជ្រើសរើស តែបុរសបែរជាយកដៃគៀសចេញ ហើយស្រដីថា ៖

- សុំចៀសឆ្ងាយៗបន្តិចមើល៍! បើចោមរោមអ៊ូអរ ជាន់កន្ទុំឥតរបៀបយ៉ាងនេះ ខ្ញុំច្បាស់ជាខ្យល់គ មិនខានទេ ។

គេសម្លក់ពួកស្រីអស់នោះ ធ្វើឫកហាក់ដូចជាមិនពេញចិត្តនឹងកិរិយារបស់នាងៗ ដែលមានចរិតជ្រួលច្រាល គ្មានសណ្តាប់ធ្នាប់ គ្មានសុជីវធម៌ទន់ភ្លន់ចំពោះភ្ញៀវ ។ រំពេចនោះ សូរទូរស័ព្ទលាន់

ឡើង ។ បុរសសង្ហាក៏លើកឆ្លើយតបយ៉ាងរហ័ស ៖

- បងមកដល់ហើយតើហ៍! កំពុងរង់ចាំអូននេះអី... តុងដែល!

រំពេចនោះ នារីសោភាមួយរូបអាយុប្រហែល២៥ឆ្នាំ ផាត់មុខលាមក្រែមម្សៅយ៉ាងឆើតសិចស៊ីស្រស់អស្ចារ្យ លេចធ្លោឡើងមកពីក្រោយខ្នងនរៈ ហើយយកទូរស័ព្ទចុចស្មារបស់គេ ៖

- សួស្តី ជិនហ្វ!
- សារី! (បុរសឧទានហៅឈ្មោះនាងទាំងមុខញញឹម)
- បែកគ្នាពីរបីថ្ងៃ មាននឹកសារីដែរទេបង?
- នរណាថាជិនហ្វមិននឹកនោះ សង្សារមួយទាំងមូលទៅហើយ?
- ហើយបើនឹកមែន ម៉េចក៏មិនឃើញទូរស័ព្ទមកអូនបន្តិចសោះ?
- ដកឃ្លាពីការងារមិនរួចនោះអី? សព្វថ្ងៃនេះ យើងមានកុងត្រាត្រូវដឹកឥវាន់ចេញទៅក្រៅប្រទេសច្រើនជាងមុន ដូច្នេះ បងត្រូវមើលចាត់ចែងអោយផលិតផលដឹកចេញទៀងទាត់ តាមកុងត្រា កុំអោយខូចមុខមាត់រោងចក្ររបស់យើង បើមិនដូច្នោះទេ លោកប៉ារបស់អូនមុខជាយិតបងស្លាប់ហើយ ។
- យី! ឥឡូវនេះ បងនិយាយខ្មែរបានឡូយណាស់តើហ៍? រៀនតែបីបួនឆ្នាំសោះ និយាយរត់មាត់ច្រឡំនឹងខ្មែរស្រុកយើងនេះដែរ ។
- មកពីបងធ្វើការជាមួយខ្មែររាល់ថ្ងៃ ហើយមានសង្សារជាខ្មែរផង ទើបបងចេះច្រើនដល់ម្លឹងនោះ ។

បន្តិចមក គេក៏ហៅអាហារបរិភោគ ។ បុរសនោះមានឫកឆ្មើងឆ្មៃ ក៏ពិតមែន តែចំពោះនារីសោភាដូចសារី គេបែរជាបន្ទន់ឥរិយាដាក់នាងយ៉ាងទន់ភ្លន់ទៅវិញ ។

- ចុះខាងសណ្ឋាគាររបស់អូនវិញ មានដំណើរការយ៉ាងណាដែរ?

ជិនហ្វសួរសង្សារ ។



- ដូចជាចេះតែទៅមុខធម្មតាទេនឹង? សារីមិនសូវនឹងទេ ព្រោះមិនដែលទៅ ។ នោះជាកិច្ចការរបស់លោកប៉ានិងបងប្រុស សារីមិនចង់នឹងឮទេ ។
- ហើយចុះអូនមិនទៅជួយធ្វើការលោកប៉ាខ្លះទេហ៍?
- មានលុយចាយមិនអស់ទៅហើយ អោយសារីទៅធ្វើការធ្វើអី? សារីចង់មានពេលជាមួយបងជាជាង ។
- តែបងក៏មិនទំនេរដូចគ្នាដែរណា៎ ត្រូវធ្វើការដូចតែលោកប៉ានិងបងប្រុសរបស់សារីអញ្ចឹង មិនដូចសារីដែលមិនចាំបាច់ធ្វើការអ្វីក៏បានដែរ ព្រោះមានលោកប៉ានិងបងប្រុសជាបង្អែកធំនោះ ។
- គឺមកពីអូនជាស្រីស្អាត...តើនរណាគេចង់ប្រើអូនដែរទៅ?

សារីធ្វើឫកខ្មិកខ្មក់ដាក់ជិនហ្វភ្លាម ។ បុរសក៏បាត់មាត់ដូចគេចុក កាលបើនាងម្រិកម្រក់អោយបុរសកើតក្ដីស្រម័យស្រើបស្រាលនៅក្នុងអារម្មណ៍របស់គេយ៉ាងភ្លើតភ្លើនស្ទើរទប់ចិត្តមិនបាន ។

- ជិនហ្វ! ថ្ងៃនេះ យើងមានពេលយូរទេ?
- មានប្រហែលជាមួយម៉ោង... អូនចង់ទៅណា?
- ទៅរកជួលអូប័រជិះដើរលេង...
- នេះក្បែរព្រលប់ហើយ... ទៅជិះអូប័រយ៉ាងម៉េចនឹងកើត?
- អញ្ចឹងទៅមើលកុនទេ? សារីចង់មានពេលវេលាខ្លះៗជាមួយបង ។ យើងជាសង្សារនឹងគ្នាពិតមែន ប៉ុន្តែបែរជាមានឱកាសជួបគ្នា ដូចជាអំពិលអំពែកអញ្ចឹង ។
- ចាំថ្ងៃក្រោយទៅនឹង ព្រោះបងត្រូវត្រឡប់ទៅរោងចក្រវិញទាំងយប់ ដើម្បីទទួលភ្ញៀវបរទេស ដែលមកសន្ទនាទាក់ទងការនាំផលិតផលចេញក្រៅ ។

សារីធ្វើមុខស្មឿក ព្រោះមិនសមបំណង ។ ការពិត អ្នកទាំង

ពីរស្គាល់គ្នាតាមរយៈការងាររកស៊ីរបស់គេ ។ ជិនហួជាជាតិចិន មកធ្វើវិនិយោគទុននៅភ្នំពេញដោយការបើករោងចក្រកាត់ដេរដើម្បីនាំផលិតផលបំរើសេវាក្នុងប្រទេសផង ទៅក្រៅប្រទេសផង ។ ឪពុករបស់គេជាពាណិជ្ជករអភិជនដ៏ល្បីម្នាក់ នៅក្វាងទុងប្រទេសចិន ។ រីឯសាវរីជាកូនមហាសេដ្ឋីម្ចាស់សណ្ឋាគារផ្កាយប្រាំនៅភ្នំពេញ ដែលមានភាគហ៊ុនពាក់កណ្តាលក្នុងរោងចក្រជិនហួ ។ នរៈនារីទាំងពីរក៏បានត្រូវណែនាំអោយស្គាល់គ្នា តាំងពីជិនហួបានមកដល់ដីខ្មែរដំបូងកាលពីជាងបីឆ្នាំមុន ។ រីឯបងប្រុសសាវរី ឈ្មោះសារៈ បានត្រូវតែងតាំងជានាយចំណាត់ការរបស់រោងចក្រជិនហួអិលធីឌី ។

ព្រលប់នោះ ធិតាធ្វើមុខហាក់ដូចមិនស្រួលក្នុងចិត្តដែលជិនហួមិនមានពេលវេលាសំរាប់នាងដូចដែលនាងទាមទារ ។ ក្រោយពីបរិភោគរួចហើយ គេក៏បែកគ្នាសាជាថ្មី ។

- យើងជួបគ្នាជាថ្មីទៀត នៅថ្ងៃណាដែរ ជិនហួ ?
- ប្រហែលជាថ្ងៃអាទិត្យ បងនឹងមានពេលពេញមួយថ្ងៃ... ចាំបងនាំអូនទៅលេងឆ្នេរកំពង់សោមម្តង ។

គ្រាន់តែឮថាឆ្នេរកំពង់សោម សាវរីញញឹមពព្រាយភ្លាមតែម្តងដោយមិនបាច់ប្រឹង ៖

- អញ្ចឹង អូនរង់ចាំបងទៅទទួលណា៎ !
- បាទ !

អ្នកទាំងពីរក៏បែកផ្លូវគ្នា ។ ជិនហួក៏បររថយន្តសំដៅទៅឫស្សីកែវដែលជាទីតាំងរោងចក្ររបស់ឪពុកនរៈមួយកន្លែង ។ តាមដងផ្លូវនោះ មានចរាចរណ៍ណែនណាន់ខ្ទាន់ខ្ទាប់ មានអ្នកស្រុកលក់ដូរតាមដងផ្លូវ និងមានកម្មកររោងចក្រដើរច្រវាត់ច្រវែងមិនដឹងជាទៅណាមកណាខ្លះទេ ។ លុះនរៈបរមកដល់ជិតមាត់ទ្វាររោងចក្រ ស្រាប់តែ



មានរថយន្តធំមួយ បរដឹកឥវ៉ាន់លើសចំណុះ បែកកង់ផ្ទុង វេចង្កូតធ្លាក់គន្លុកដីធំមួយ ផ្អៀងតួឡានជ្រុះធ្លាក់ឥវ៉ាន់ប្រាវ មកលើតួរថយន្តដ៏សង្ហាររបស់បុរសជាតិចិននោះ ឥណ្ឌប់ចង់ជិតអស់តួឡានថែមទាំងសង្កត់លើរ៉ឺម៉កម៉ូតូដឹកមនុស្សមួយចំនួនទៀត កប់បាត់អ្នកដំណើរមិនដឹងជាស្លាប់រស់ឫរបួសអស់ប៉ុន្មាននាក់ទេ ។ អ្នកស្រុកក៏ផ្អើលជ្រួលច្រាលឡើងអ៊ូអរ ស្ទុះចរាចរកកគាំងលែងទៅណារួចតែម្តង ។ ស្ហូហ្វ័រឡានធំនោះភិតភ័យណាស់ ក៏រត់ចុះពីឡានរត់ត្រុយ បន្លំខ្លួនបាត់ទៅក្នុងចំណោមមនុស្សរយពាន់នោះបាត់ទៅ ។ ចំណែកអ្នករងគ្រោះក៏ត្រូវគេសង្គ្រោះចេញម្តងមួយៗ ។ ចៃដន្យអី នៅពេលគេកាយយកឥវ៉ាន់ចេញពីតួឡានរបស់ជិនហួរួច គេឃើញនាយត្រូវអំបែងកញ្ចក់មុតឈាមពេញខ្លួន ។ ស្រាប់តែពួកហ្វូងកម្មករដែលរត់មកជួយទាំងនោះ បែរជានាំគ្នាដើរថយក្រោយក្រាកៗ មិនព្រមចូលជិតទៅសួរអ្វីជាមួយបុរសនោះឡើយ ។ រំពេចនោះ ស្រាប់តែនារីមួយរូបក្នុងវ័យប្រហែល២០ឆ្នាំ មានស្ពាយសាក់កាដូមួយនៅលើខ្នងផង បានឧទានឡើងថា ៖

- ហេតុអ្វីហ្នឹ៎ ឃើញមនុស្សរបួសហើយមិនជួយដូច្នេះ ?

មាណវីក៏ស្ទុះទៅជិត ជួយបើកទ្វារឡាន តែបើកមិនចេញ ត្បិតទ្វារនោះត្រូវរបស់របរធ្លាក់សង្កត់កំពិតរួញចូលក្នុង ។ នាងក៏ស្ទុះរត់ទៅបើកនៅទ្វារម្ខាងទៀត ស្រាប់តែមានកម្មការិនីមួយរូបទាញដៃនាងទៅឱ្យបប្រាប់ថា ៖

- កុំទៅចង់ធ្វើបុណ្យជាមួយពួកអាចៅកែអ្នកមានអស់ហ្នឹង ! វាមិនចេះស្គាល់បុណ្យគុណទោសអីទេ ។ វាចេះតែហុតឈាមអ្នកក្រតែម្យ៉ាងប៉ុណ្ណោះ ។ អោយឈាមអាក្រក់វាហូរចេញខ្លះក៏ល្អហើយ នោះវានឹងបានដឹងថា ហុតឈាមអ្នកក្រលើសចំណុះ នរកវាតាមទារវិញ

យ៉ាងងាយៗ ដូច្នេះឯង ។

តែមាណវីជ្រួញចិញ្ចើម មិនយល់ថាគេនិយាយនោះ សំដៅបុរសនោះតែម្តង ឬក៏គ្រាន់តែជាភាសាដែលអ្នកក្រស្អប់អ្នកមានជាទូទៅព្រោះអ្នកមានចូលចិត្តជិះជាន់អ្នកក្រ ? នាងឃើញអ្នករបួសនោះទន់ករងាក ក៏ស្រដីថា ៖

- ឃើញមនុស្សទុរន់ទុរាហើយ មិនជួយក៏មិនកើត តែបើជួយទៅខ្លាចប៉ះមនុស្សមិនល្អ តើធ្វើម៉េចទៅហ្ន៎ ?

មនុស្សម្នាចោមជិតឡាន តែគ្មាននរណាឈឺឆ្អាលជួយបើកទ្វារនោះយកបុរសនោះចេញមកក្រៅទេ ។ មើលទៅគេ ទំនងដូចជាត្រូវក្បាលយ៉ាងដំណំហើយ ទើបឃើញទន់ខ្លួនធ្វើងីងើនិយាយអ្វីមិនរួចដូច្នេះ ។ ទ្រាំមើលនឹងភ្នែកមិនបាន ធិតាមួយរូបនោះក៏អើតតាមចន្លោះបង្អួចម្ខាងទៀត សួរថា ៖

- នែ៎! អ្នកម្ចាស់ឡាន! នឹងខ្លួនទេ ? អាចព្រមៀលខ្លួនចេញខាងនេះបានទេ ? ចាំខ្ញុំនឹងបើកទ្វារខាងនេះអោយចេញ ។

បុរសនោះប្រឹងបែកភ្នែកទាំងឈឺចាប់ ។ ឯឈាមក៏ហូរពីក្បាលស្រក់មកលើផ្ទៃមុខជិតពេញស្ទើរលែងឃើញមុខទៅហើយ ។ កាលបើបែរឃើញនារីយេិងបើកទ្វាររថយន្តម្ខាងទៀតអោយ គេក៏រំកិលខ្លួនទាំងទុរន់ទុរាចេញមក ។ មើលទៅគេក៏មានរបួសគួរសមដែរសុទ្ធតែអំបែងកញ្ចក់មុតពេញខ្លួន តែប្រហែលជាមិនដល់ថ្នាក់បាក់ឆ្អឹងបាក់ឆ្អែងនោះទេ ព្រោះគេនៅកំរើកខ្លួនបានតាមសម្រួល ។

រំពេចនោះ ធិតាក៏សួរបុរសម្នាក់អាយុប្រមាណប្រហែល៣០ឆ្នាំកំពុងជិះម៉ូតូដែកឈប់គាំងស្ទះក្នុងចរាចរម៉ូតូៗនោះដែរ ៖

- ល្បងៗ! ជួយឌុបគាត់នោះទៅពេទ្យបន្តិចបានទេ ?

បុរសនោះសម្លឹងមុខនារីធ្វើភាំង មិនឃើញឆ្លើយទេ ។ នាងក៏



សួរទៀតថា ៖

- បងរត់ម៉ូតូឌុបទេ ? បើរត់ ដឹកគេនេះទៅពេទ្យបន្តិចទៅ ឃើញមនុស្សរបួសហើយមិនជួយ ដូចជាអត់ចិត្តពេកណាស់ ។

អ្នកស្រុកឈរមើលម៉្លំនោះក៏ធ្វើមុខភាំងដូចគ្នា ។ ស្រាប់តែមានមនុស្សម្នាក់លាន់មាត់ថា ៖

- នាងប្រហែលជាអ្នកចម្ងាយហើយ បានជាមានកិរិយានិងសំដីខុសគេយ៉ាងនេះ ។ បើសិនជាអ្នកស្រុកម៉្លំនេះវិញ គេទុកកិច្ចការនោះឲ្យប៉ូលីសធ្វើការហើយ ព្រោះអ្នកស្រុកយើងមិនចូលចិត្តលូកលាន់រឿងរ៉ាវរបស់ពួកអ្នកមាន នាំតែជ័រភ្លៅស្អិតជាប់ឃ្លៀកទទេៗនោះទេ ។ ពួកអ្នកមានវាមិនដែលស្គាល់គុណស្រ័យ និងសមានចិត្តរបស់អ្នកក្រដូចពួកយើងនេះ ម្តងណាឡើយ ។

នារីនោះឮហើយក៏ស្រដីខ្សិបៗក្នុងមាត់តែម្នាក់ឯងថា ៖

- នរណាថាខ្ញុំជួយដោយមិនគិតសគុណ ? ពុទ្ធោ...! នរណាមិនស្គាល់ ?... រាសីស្មោះ! មិនអោយរបូតងាយៗឡើយ ព្រះអង្គ!

អូហ៍! ការពិតគឺរាសីរបស់យើងទេតើហ៍! ចុះហេតុអ្វីមកដល់ភ្នំពេញនេះទៅវិញ ?

បុរសជិះម៉ូតូនោះមិនឆ្លើយនឹងនារីយើងថាយ៉ាងណាទេ គ្រាន់តែសម្លឹងមុខនាង ហាក់ដូចជាចាប់អារម្មណ៍រឿងអ្វីម្យ៉ាង រួចហើយគេក៏ឈប់ម៉ូតូជួយទប់ជិនហួ អោយឡើងអោបចង្កេះរបស់គេពីខាងក្រោយ ដើម្បីដឹកយកទៅមន្ទីរពេទ្យ ។

- ជួយយកកាតាបដាក់ឯកសារពីឡានអោយខ្ញុំផង! (ជិនហួស្រដីពីងនារីយើង រួចហើយក៏លើកទូរសព្ទ័ហៅគ្នីគ្នា)

រាសីក៏ស្ទុះទៅបើកទ្វារឡាន ស្រវាកាតាបខ្មៅដាក់ឯកសាររបស់ជិនហួចេញមក ស្រាប់តែភ្លាត់ដៃជ្រុះកាតាបនោះកំពប់លើពូកឡាន

ចេញឯកសារព្រោងព្រាត ។ នាងដាក់ភ្នែកទៅឃើញក្រដាសមួយសំណុំកិបជាប់គ្នា មានបោះត្រាពណ៌ក្រហមថា ឯកសារសម្ងាត់ ។ នាងភ្ញាក់ព្រើតលួចចោលកន្ទុយភ្នែកសម្លឹងទៅម្ចាស់រថយន្ត ឃើញគេកំពុងយកដៃជូតឈាមដែលហូរពីក្បាលចូលភ្នែក ។ នាងក៏ស្រវាប្រមូលក្រដាសឯកសារទាំងនោះទុកវិញជាប្រញាប់ រួចបិទកាតាបយួរចេញមក ។ បុរសម៉ូតូក៏រោទិ៍ម៉ាស៊ីន ម៉ូតូបំរុងចេញទៅ ។

- ឈប់សិន! កុំលឿនពេក! ខ្ញុំទៅដែរ ។

រាសីនិយាយហើយ ក៏ហក់ឡើងជិះច្រកកៀវពីក្រោយបុរសទាំងពីរយ៉ាងរហ័ស ធ្វើឲ្យមនុស្សឈរមុំនោះ គេមើលច្រូងច្រាងព្រោះចម្លែកចិត្ត ដែលឃើញមនុស្សស្រីស្លៀកខោអាវប្រុស សំដីក្លាហានមានចរិតដូចប្រុសយ៉ាងដូច្នោះ ។ ភ្លាមនោះ ប៉ូលីសមួយហ្វូងបានមកដល់កន្លែងកើតហេតុដែរ ។ ចៃដន្យ ជិនហួបានចេញបាត់ពីមុំនោះបាត់ទៅហើយ ។

បុរសម៉ូតូឌុបដឹកអ្នករបួសនិងរាសី មកដល់គ្លិនិកមួយមិនឆ្ងាយប៉ុន្មានពីទីគ្រោះថ្នាក់នោះទេ ។ តែដោយភាពអ៊ូអរ និងការស្ទះចរាចរ គេចំណាយពេលជិតកន្លះម៉ោង ទំរាំនាំជិនហួមកដល់គ្លិនិកនោះ ។ លោកគ្រូពេទ្យប្រចាំគ្លីនិកក៏រត់ចេញមកទទួលយកអ្នករបួសចូលភ្លាម ។ រាសីអង្គុយលើកៅអី យកដៃគោះកាតាបដាក់ឯកសាររបស់ជិនហួប៉ិកប៉ក់ៗ នៅខាងក្រៅក្បែរមាត់ទ្វារគ្លិនិក ។ ចំណែកបុរសម៉ូតូឌុបចេះតែលួចសម្លឹងមុខនារីភ្លៀកៗ មិនព្រមដាក់ភ្នែកសោះ មិនដឹងថាគេកំពុងគិតអ្វីពីនាងទេ ៖

- នែ៎! កុំសូវមើលមុខខ្ញុំពេកមើល៍! (រាសីគំហកអោយ) ម៉េចខ្លាចខ្ញុំមិនមានលុយអោយថ្លៃម៉ូតូ ហីយ៉ាំងម៉េច បានជាមើលមុខខ្ញុំមិនព្រមឈប់យ៉ាំងនេះ ?



បុរសនោះឮវាចារបស់នាងភ្លាម ក៏ញញឹម ហើយបែរទៅម្ខាងនៅស្ងៀម មិនតបមិនស្រដីអ្វីទៅនាងវិញទេ ។ បន្តិចមក គេក៏លួចចោលកន្ទុយភ្នែកលួចមើលធិតាទៀតសាជាថ្មីដដែល ។ ឃើញដូច្នោះ រាសីក៏ដោះមួកហើយដើរទៅជិត រួចស្រដីសួរនាយម៉ូតូឌុបបន្តទៀតថា ៖

- នែ៎ល្បងម៉ូតូឌុប! មានកាម៉ារ៉ាថតរូបទេ ?

បុរសនោះភ្ញាក់ព្រើត គ្រវីក្បាល តបវិញថា ៖

- បាទ! អត់មានទេ! អ្នកនាងត្រូវការយកទៅថតកន្លែងកើតហេតុមែនទេ ?

- នរណាថា ? ខ្ញុំចង់បានកាម៉ារ៉ា យកមកអោយល្បងឯងជួយថតរូបខ្ញុំ ឬនងប់ប៉ុស្ត៍លេង ។

- អូហ៍ អ្នកនាងថតរូបយកទៅចុះឈ្មោះធ្វើការនៅឯណាមែនទេ ?

- អត់ទេ! គឺចង់ថតអោយល្បងឯងយករូបខ្ញុំទៅផ្ទះ ដេកមើលអោយណាណីតែម្តងទៅ កុំអោយពិបាកចោលកន្ទុយភ្នែកលួចមើលខ្ញុំ ឡើងស្រឡៀវភ្នែកបែបនេះច្រើនពេក ។ ខ្ញុំខ្លាចល្បងឯងក្លាយជាជនស្រឡៀវតេវ កៃលែងឡើង!

បុរសនោះហាក់ដូចរអៀសខ្លួនបន្តិចដែលនាងនិយាយចំៗ តែក៏លួចញញឹមក្របួចមាត់ ចង់សើចបន្តិច ខ្មាស់បន្តិច ព្រោះមាណវីមានសំដីរួសរាយគួរអោយចូលចិត្ត ។ រំពេចនោះ បុរសយកដៃខ្ទប់ដើមទ្រូងឆ្វេងរបស់ខ្លួន ហើយស្រដីថា ៖

- តែ...កាម៉ារ៉ាពិសេសក្នុងទ្រូងឆ្វេងរបស់ខ្ញុំនេះ បានថតរូបអ្នកនាងទុកហើយ ។ ចាំយប់នេះ ខ្ញុំនឹងយកហ្វិលមកចាក់សាថ្មី គេងមើលអោយពេញម៉ាយប់ ទាល់តែអស់ចិត្តខ្ញុំតែម្តង ។

ស្រាប់តែនាងសើចខឹកៗឡើង ឆ្លើយថា ៖

- យ៉ាងណា សូមមេត្តាកុំតែធ្លាក់ពីលើគ្រែបានហើយណា៎!
- បើសិនខ្ញុំធ្លាក់ពីលើគ្រែមែន តើមាននរណាគេទៅហ្ន៎ មកជួយយកអាសារ លើកខ្ញុំដាក់ចូលក្នុងមុងលើគ្រែវិញ ?
- ខ្ញុំថាប្រហែលជាមូសហើយមើលទៅដែលចិត្តល្អជាងគេនោះ ។

បុរសនោះអត់មិនបានក៏លាន់សំណើចខឹកៗឡើង ។ ពេលនោះ រាសីសង្កេតឃើញថា នរៈក៏ហាក់ដូចជាមានចិត្តចង់និយាយជាមួយនាងច្រើន គ្រាន់តែគេមិនដឹងថាត្រូវចាប់ផ្ដើមការសន្ទនាយ៉ាងណា ទើបគេយកកន្ទុយភ្នែកជាគោលសញ្ញា អោយនាងចាប់អារម្មណ៍ថា គេកំពុងតែចង់ប្រស្រ័យសន្ទនាជាមួយនាង ។ ចៃដន្យ រាសីមិនមែនជានារីអៀនប្រៀនខ្មៀនកៀនជញ្ជាំងនោះទេ ។ នាងជាមនុស្សក្លាហាន បានមាត់បានកតាំងតែពីដើមមក មិនសូវចេះតមមាត់រឿងអ្វីឡើយ ។ ពេលនោះ អ្នកទាំងពីរក៏ចាប់ផ្ដើមមានរឿងជជែកផ្គោះផ្គងគ្នាទៅវិញទៅមក យ៉ាងសប្បាយសើចកក្អឹកតែម្ដង ។

បន្តិចមក លោកគ្រូពេទ្យនាំជិនហ្វូចេញមកវិញ ។
- លោកអោយថ្លៃព្យាបាលគេហើយមែនទេ ? (រាសីសួរ)

ជិនហ្វូងក់ក្បាល លួចសម្លឹងមុខនារីយើងភ្លៀកៗ ។ ភ្លាមនោះ រាសីក៏សួរជិនហ្វូទៀតថា ៖
- ចង់អោយខ្ញុំជូនទៅផ្ទះទេ ?

ជិនហ្វូសម្លឹងមុខនាងមួយស្របក់ ក៏ងក់ក្បាល ហើយស្រដីតបទាំងទឹកមុខនៅឈឺចាប់ដោយសាររបួសនៅឡើយ ថា ៖
- បាទ! គឺសូមជូនខ្ញុំទៅរោងចក្រជិនហ្វូ អិលធីឌី ផង ។

បន្តិចក្រោយមក បុរសម៉ូតូឌុបបាននាំជិនហ្វូនិងរាសីមកដល់មុខរោងចក្រ ដែលមានឆ្មាំពីររូបឈរចាំយាមផែកឆេវ ។ ជិនហ្វូចុះពីម៉ូតូហើយក៏ស្រដីថា ៖



- អរគុណអ្នកទាំងពីរដែលមកជួយខ្ញុំថ្ងៃនេះ ។

គ្រាន់តែក្រឡេកឃើញវត្តមានជិនហ្វូភ្លាម ឆ្មាំទាំងពីរស្ទុះរឹងមកទទួលស្វាគមន៍ ៖
- ជំរាបសួរលោកជិនហ្វូ!

រាសីភ្ញាក់ព្រើត នឹកក្នុងចិត្តថា ៖
- លោកជិនហ្វូ ?...ជាថៅកែរបស់រោងចក្រជិនហ្វូអិលធីឌីតើហ៍!

ជិនហ្វូរៀបនឹងដើរចូលទៅក្នុងរបងរោងចក្រទៅ ហើយស្រាប់តែរាសីស្រែកឡើងពីក្រោយ ថា ៖
- ចៃដន្យ យើងជាអ្នកក្រ មានសមានចិត្តជួយលោកពិតមែន តែកុំភ្លេចថ្លៃលើកទឹកចិត្តអ្នកក្រផង ដើម្បីអោយសមនឹងមុខមាត់របស់ថៅកែរោងចក្រទាំងមូល... សូមមេត្តាកុំដើរបែរខ្នងចេញដោយមិនបានបង្ហាញសមានចិត្តតបយើងវិញ ចំពោះការដែលយើងបានធ្វើចំពោះលោកនៅថ្ងៃនេះ ព្រោះថា បើធ្វើដូច្នោះមែន គឺហាក់ដូចជាបង្ហាញនូវភាពអាត្មានិយមរបស់អភិជនពន់ពេកណាស់ ។

ជិនហ្វូភ្ញាក់ព្រើតបែរក្រោយសម្លឹងមុខយុវនារីយើងយ៉ាងរហ័សតែម្ដង ។ មែនហើយ! អំបាញមិញ គេរវល់តែនឹកគិតដល់រឿងជំនួបជាមួយពាណិជ្ជធំៗ មកពីបរទេស ក្នុងរោងចក្ររបស់គេ នាព្រលប់នេះ ម្ល៉ោះហើយ គេក៏ភ្លេចអោយឈឹងរឿងថ្លៃម៉ូតូឌុបនិងថ្លៃលើកទឹកចិត្តនារីអស់រលីង ។ ណាមួយ គេធ្លាប់ធ្វើតែជាថៅកែវាយឫកឆ្មើងឆ្មៃ មានអ្នកបំរើឆ្វេងស្ដាំ ហុចនេះហុចនោះតាមតែគេត្រូវការ មិនចាំបាច់នឹកគិតថាត្រូវសម្ដែងសទ្ធា លើកទឹកចិត្តដល់នរណាម្នាក់នៅក្នុងរោងចក្រសោះឡើយ ។ លុះដល់គេមកប្រទះឧប្បត្តិហេតុថ្ងៃនេះ គេក៏ភ្លេចខ្លួនថា គេកំពុងជំពាក់សមានចិត្តរបស់អ្នកស្រុកដែលមិនមែនជាកម្មករស៊ីប្រាក់ខែរបស់រោងចក្រ ។ កាល

បើឮសំដីថ្លៃផ្ការបស់មាណវីយើង គេក៏ភ្ញាក់ខ្លួនក្រញាង នឹកខ្មាសឆ្នាំទ្វារពីរនាក់នោះដល់សួរហើយ ត្បិតនារីយើងស្រដីឮខ្លាំងៗ មិនមាននឹកក្រែងរអែងចិត្ត ។

ជិនហ្វូដកដង្ហើមបន្ទូរទ្រូងមួយ រួចក៏ទាញកាបូបដកលុយពីរបីសន្លឹកហុចអោយនារី ដែលកំពុងឈរច្រត់ចង្កេះចាំទទួលក្បែរនាយម៉ូតូឌុប ។ ធិតាទទួលយកមកលាតមើល ស្រាប់តែភ្ញាក់ព្រើត ត្បិតនោះជាប្រាក់បីដុល្លារតែប៉ុណ្ណោះ ៖

- ពុទ្ធោអើយ! យើងខំប្រឹងជួយលោកម៉ាំងើ បានត្រឹមតែបីដុល្លារប៉ុនហ្នឹងទេហ៍? អីក៏ចិត្តល្អម្ល៉េះ លោកអ្នកមាន?

ជិនហ្វូជ្រួញចិញ្ចើមហើយស្រដីតបថា ៖

- ថៃដន្យ ខ្ញុំមានរាយតែប៉ុនហ្នឹងឯង ។ ថ្លៃម៉ូតូឌុបតែប្រាំកាក់ទេ ដូច្នេះចំណែកពីរដុល្លារកន្លះដែលនៅសល់ គឺជារបស់នាងហើយ ។ ប៉ុនហ្នឹងហាក់ដូចជាច្រើនពេកផង សំរាប់ការងារដែលនាងធ្វើជាងពីរម៉ោងកន្លងមក ។ បើនាងធ្វើកម្មកររោងចក្រវិញ ប្រាក់ការងារ ៨ម៉ោងបានតែមួយដុល្លារកន្លះទេ ក្នុងមួយថ្ងៃ ។ ដូច្នេះ អ្វីដែលនាងបានទទួលឥឡូវនេះ គឺលើសចំនួនពីប្រក្រតីហើយតើហ៍!!

ថាហើយ ជិនហ្វូដើរចូលទៅក្នុងរោងចក្រធ្វើមិនដឹង ហាក់ដូចជាមិនខ្វល់នឹងអារម្មណ៍របស់នរណាឡើយ ។ រាសីក៏កើតចិត្តមោហោភ្លាម ហើយក៏ខាំធ្មេញក្រឹតៗ ស្រដីខ្សិបៗតែក្នុងមាត់ពីក្រោយខ្នងជិនហ្វូ ថា ៖

- ស្មានថាអ្នករួចខ្លួនហើយហ្នឹង លោកចៅកែ? យើ! កុំច្រឡំស្មានថារួចខ្លួនអោយសោះ... រាសីមិនអោយអ្នកដើរខ្សែលើងាយៗដូចអ្នកបានគិតនោះឡើយ... បន្តិចទៀត អ្នកគង់តែមករកខ្ញុំវិញ ដើម្បីទទូចអង្វររាសីយើងជាក់ជាមិនខាន ។



ថាហើយ នាងក៏ហុចពីរដុល្លារអោយទៅបុរសម៉ូតូឌុប ៖

- នេះ ថ្លៃសាំងម៉ូតូរបស់ល្បង! យកទៅ!

បុរសនោះសម្លឹងមុខនារី រួចលូកដៃទទួលយកប្រាក់ បន្តិចមកក៏អាប់អោយធិតាវិញ ពីរពាន់រៀល (ប្រាំកាក់) ៖

- នេះ យើងចែកគ្នាម្នាក់ពាក់កណ្តាលចុះណា៎ យ៉ាងម៉េចដែរ?

- អត់ទេ! (រាសីតប) ល្បងចេញថ្លៃសាំងម៉ូតូ ចំណែកខ្ញុំមិនមានចំណាយអ្វីទេ គ្រាន់តែហត់មាត់ប៉ុនហ្នឹង មិនគួរយកច្រើនជាងល្បងឯងទេ ត្បិតហាក់ដូចជាប្រមាថកម្លាំងអ្នកក្រគ្នាឯងណាស់ ។ ខ្ញុំយកតែមួយដុល្លារសមរម្យហើយ ។

ដោយឃើញមានសមានចិត្តចំពោះខ្លួនដូច្នោះ គេក៏សួរថា ៖

- ចង់អោយខ្ញុំជូនអ្នកនាងទៅខាងណាទេ ឥឡូវនេះ? ខ្ញុំសូមជូនមួយជើងដោយឥតគិតថ្លៃឈ្នួលទៅចុះ គិតថា ខ្ញុំជូនជាសមានចិត្តដែលអ្នកនាងជួយរកម៉ូយម៉ូតូឌុបថ្ងៃនេះមកអោយខ្ញុំ រហូតដល់បានប្រាក់ពីរដុល្លារឯណោះ ។

រាសីឈរអោបដៃធ្វើម៉ក់មួយស្របក់ទើបនិយាយថា ៖

- ការពិត រាសីខ្ញុំនេះគ្មានផ្ទះដែលត្រូវទៅទេ ព្រោះទើបធ្វើដំណើរមកពីបាត់ដំបង ដល់ភ្នំពេញ ប៉ុន្មានម៉ោងមុននេះឯង ។

- អូហ៍! អញ្ជឹងអ្នកនាងនឹងទៅស្នាក់នៅឯណាទៅ?

- មិនទាន់ដឹងទេ ចាំរក្សាប្អូនប្រុសខ្ញុំ គេត្រឡប់មកពីរកជួលបន្ទប់ស្នាក់នៅសិន ។ ពេលនេះ មិនដឹងថារកបានឬក៏យ៉ាងណាទេ ព្រោះយើងកំពុងនាំគ្នាមករកការធ្វើនៅភ្នំពេញនេះ ។

- ហើយចុះអ្នកនាងត្រូវទៅជួបប្អូនប្រុសវិញ នៅឯណាដែរ?

- គឺនៅម្តុំៗគល់ចាមរីមួយក្បែរកន្លែងកើតហេតុអំបាញមិញ...

- អញ្ជឹង ឡើងម៉ូតូមក ខ្ញុំជូនត្រឡប់ទៅវិញ ។

រាសីក៏ហាក់ថ្លាញ ឡើងច្រកកៀវលើម៉ូតូតោងចង្កេះបុរសយើងចេញទៅភ្លាម ។ រីឯនរៈវិញ ហាក់ដូចជាលួចញញឹមតែម្នាក់ឯងលាក់គំនួចតែក្នុងចិត្ត ដោយបាននារីជិះតោងចង្កេះ ។ គេក៏បរម៉ូតូយឺតៗកាត់ចរាចរណ៍ណែនណាន់ខ្ពាន់ខ្ពាប់ដូចត្រីពុលទឹក តម្រង់ទៅរកទីចាស់ ។

មួយសន្ទុះមក គេក៏រករក្សាឃើញ ។ រក្សាក៏ប្រាប់បងស្រីថា ៖

- រកបន្ទប់ជួលបានហើយបង! មួយខែដល់ទៅ១០ដុល្លារឯណោះ គ្រាន់តែជាកូនផ្ទះឈើមួយមានចែកបន្ទប់ៗ ហើយខ្ញុំកក់គេយកបន្ទប់មួយហើយ នៅជិតរោងចក្រជិនហួអិលធីឌី ។

គ្រាន់តែឮឈ្មោះនេះភ្លាម រាសីភ្ញាក់ព្រើតបើកភ្នែកធំៗ នឹកក្នុងចិត្តតែម្នាក់ឯង ៖

- តើរាសីយើងនេះមានជាប់ជំពាក់និស្ស័យអ្វីជាមួយម្ចាស់រោងចក្រនេះទេនឹង បានជាមានហេតុការណ៍នាំគន្លងអោយយើងដើរប្រទាក់ក្រឡាជីវិតគ្នារបៀបនេះ ?

ភ្លាមនោះ បុរសម៉ូតូឌុបស្រដីថា ៖

- តើអ្នកទាំងពីរចង់អោយខ្ញុំជូនទៅដល់ផ្ទះជួលនោះដែរទេ ?

- គឺ... មិនបាច់ទេនឹង នាំតែរំខានដល់ពេលវេលារកស៊ីរបស់ល្បងទេ ណាមួយយើងក៏មិនជាសំបូរប្រាក់បង់ថ្លៃម៉ូតូឌុបផង ។

- មិនអីទេ! ចាត់ទុកថាជាសមានចិត្តនៃការរាប់អានរវាងយើងទាំងបីនាក់ចុះណា៎! ខ្ញុំមិនគិតគូរថ្លៃឈ្នួលទេ ។

បុរសម៉ូតូឌុបក៏បរជូនអ្នកទាំងពីរទៅរកផ្ទះជួលនោះដល់កន្លែងត្រឹមត្រូវ ទើបគេបែកផ្លូវត្រឡប់ទៅវិញ ។

នៅព្រលប់ដែលនោះ...

- រក្សា! ស្អែកនេះប្អូនទៅរកសាលាចុះឈ្មោះចូលរៀន ។ ចំណែក



បងវិញ គិតដើររកការធ្វើម្ដុំៗនេះចុះ ។

- តើបងសង្ឃឹមទេ ថានឹងបានការធ្វើឆាប់ៗ ?

- បងមិននឹងទេ! បើយើងព្យាយាម គង់តែបានសំរេចទេ រក្សា!

- នៅភ្នំពេញនេះ បើគ្មានការធ្វើ យើងច្បាស់ជាដាច់ពោះហើយកុំថាឡើយដល់ទៅមានលុយបង់សាលានោះ ។

- មិនទាន់ចូលសង្វៀនប្រយុទ្ធផង ម៉េចក៏រៀបចិត្តបំរុងទទួលការចុះចាញ់ទៅហើយ ? បងគិតថា យើងនឹងមានលាភឆាប់ៗនេះ!

- អូហ៍... អ្វីទៅដែលនាំអោយបងមានជំនឿដល់ម្លឹងនោះ ?

- គឺប្រាជ្ញរបស់បងនោះអី... វានឹងប្រមូលលាភដល់បងនិងរក្សាជាមិនខាន មិនយូរមិនឆាប់ ចាំមើលចុះ!

រក្សាញញឹមហើយក៏ទំរេតក្បាលលើខ្នើយសំងំគេង ទុកឲ្យរាសីអង្គុយផ្ទៀងក ពិនិត្យក្រដាសប្អូនដប់សន្លឹកតែម្នាក់ឯង ។

តុក! តុក! តុក! សូរគោះទ្វារ ។

- នរណាហ្នឹង ? (រាសីសួរពីខាងក្នុងបន្ទប់ទៅ)

- គឺខ្ញុំ សយនា! (សម្លេងបុរសម្នាក់ឆ្លើយ)

- ខ្ញុំគ្មានញាតិឈ្មោះហ្នឹងទេ! អ្នកមករកបងប្អូនច្រឡំបន្ទប់ហើយ!

- មិនច្រឡំទេ... គឺត្រូវបន្ទប់ហើយ បើកទ្វារអោយបន្តិចមក ។

រាសីពិភាល់ក្នុងចិត្តណាស់ មិនហ៊ានបើកទ្វារបន្ទប់អោយមនុស្សចម្លែកទេ មិនដឹងថាគេមានបំណងអ្វីទាំងយប់ ។ តែលុះឮសូរគោះច្រើនដងពេក ខ្លាចរំខានដល់អ្នកជាប់បន្ទប់ រាសីក៏ដើបទៅបើកទ្វារឡើង ស្រាប់តែប្រទះនឹងបុរសម៉ូតូឌុបដែលនាងជួបពីថ្ងៃមិញនោះកំពុងឈរសើចញញឹមដាក់នាង ព្រមទាំងមានយួរឥវ៉ាន់មួយស្បោងមកជាមួយផង ។

- អូហ៍! ល្បងឈ្មោះសយនាតើហ៍ ?

សយនាញញឹមឡើងកាលបើឃើញធិតាបើកទ្វារអោយ ៖

- សួស្តីរាសី! នៅចាំមុខខ្ញុំបានដែរមែនទេ ?

មាណវីភ្ញាក់ព្រើត ឆ្លើយឡើង ៖

- ហេតុអ្វីល្បងស្គាល់ឈ្មោះខ្ញុំដែរ ? ហើយមានការអ្វីទៅទាំងយប់ព្រលប់យ៉ាងនេះ ?

នរៈញញឹមមិនឆ្លើយទេ ត្បិតឆវីបានភ្លេចទៅហើយថានាងធ្លាប់ហៅខ្លួននាងថា រាសី នៅចំពោះមុខបុរសយើង ។ គេបែរជាសួរត្រឡប់ទៅនាងវិញថា ៖

- ចុះបើខ្ញុំមានចំណីបន្តិចបន្តួច យកមកផ្ញើ ដើម្បីបរិភោគជុំគ្នានៅទីនេះ តើរាសីអនុញ្ញាតដែរទេ ?

- គឺ... ខ្ញុំនឹងរក្សាបានបរិភោគបន្តិចបន្តួចរួចហើយ!

- អញ្ចឹង មកទទួលទានជាមួយខ្ញុំម្តងទៀតទៅណា៎ ព្រោះខ្ញុំមិនចង់បរិភោគតែម្នាក់ឯងទេ ព្រោះដូចជាត្រមង់ត្រមោចណាស់ ។

- ចុះល្បងគ្មានប្រពន្ធកូនឬក្រុមគ្រួសារអ្វីទេ បានជា... ?

ភ្លាមនោះ សយនាបែរជានិយាយកាត់ភ្លាមថា ៖

- ម៉ោះ! នេះត្រីអាំងជ្រក់ត្រសក់លាយសណ្តែក ហើយនឹងស្ងោរម្រះ ។ ឯណាចាន ?

ការពិត រាសីនិងរក្សាបានបរិភោគបាយសម្រួបដែលគេលក់នៅមាត់ផ្លូវអស់ម្នាក់មួយចានរួចទៅហើយមែន ប៉ុន្តែគ្រាន់តែបានមួយសំរន់តែប៉ុណ្ណោះមិនជាបានឆ្អែតពេញពោះទេ ត្បិតគេចង់សំចៃប្រាក់មិនអោយចាយអស់មុនពេលដែលគេរកការធ្វើបាន ។ មុននឹងធ្វើដំណើរភ្នំពេញនេះ អ្នកទាំងពីរបានលក់ដីដែលនៅសល់មួយជ្រុងឯព្រៃកូនខ្លាបាត់ដំបង បានប្រាក់បន្តិចបន្តួចទុកជាទុន មកភ្នំពេញរកការធ្វើ ក្រែងរកលុយបានអោយរក្សាបង់ថ្លៃសាលា ព្រោះរក្សា



ចង់រៀននៅមហាវិទ្យាល័យនឹងគេ បន្ទាប់ពីនាយប្រឡងជាប់មធ្យមសិក្សាមក ។

កាលបើឃើញអាហារមកដល់ទំនងដូចឆ្ងាញ់ រាសីរកប្រកែកមិនរួចសោះ ។ នាងក៏ដាក់សន្លឹកក្រដាសទាំងនោះចុះទៅម្ខាង រួចក៏ស្រវាចានមកចាប់អាហារចែកគ្នាបរិភោគ ។ ចៃដន្យ រក្សាមិនព្រមដើបមកទេ បែរជាឆ្លើយថាងងុយគេងណាស់ ។ រាសីក៏នៅអង្គុយបរិភោគជាមួយនរៈយើងតែពីរនាក់ ។ បន្តិចមក ឆវីក៏លើកយកចានទៅលាង ។ សយនាអង្គុយស្ងៀមតាមសម្លឹងមាណវី មិនដាច់ក្រសៃភ្នែក ហើយលួចញញឹមតែម្នាក់ឯង ហាក់ដូចជារីករាយក្នុងចិត្ត ដែលគេបានបរិភោគបាយជាមួយនាង ។ រំពេចនោះមាណពដាក់ភ្នែកចុះទៅចំក្រដាសបួនដប់សន្លឹកដែលរាសីដាក់ចោលក្បែរនោះ ។ គេក៏លើកឡើងយកមកអាន ស្រាប់តែបើកភ្នែកធំៗតែម្តង ។ លុះឮសូរសម្រិបជើងរាសីដើរចូលមកក្នុងបន្ទប់វិញ នរៈយើងក៏ប្រញីប្រញាប់ទម្លាក់ក្រដាសចុះយ៉ាងរហ័ស មិនអោយធិតាចាប់ថ្នាក់បានថានាយលួចអានសំណៅផ្ទាល់ខ្លួនរបស់នារីទេ រួចហើយក៏រៀបឫកពាររបស់ខ្លួនដូចប្រក្រតីវិញ ។

រាសីឃើញសយនាអង្គុយស្ងៀមស្ងាត់ ក៏សួរនរៈថា ៖

- ល្បងជាអ្នកភ្នំពេញនេះមែនទេ ?

- បាទ! ហើយចុះរាសីវិញ ជាស្រី ជាប្រុស ឬក៏ខ្ទើយ ? ហៅខ្ញុំសុទ្ធតែ ល្បងៗ មើលតែខ្លួនហ្នឹងជាប្រុសអញ្ចឹង!

- យី! ល្បងនិយាយអីអញ្ចឹងទេ ពិបាកស្តាប់ដល់ហើយ!

- ម៉េចក៏ថាពិបាក ? គឺខ្ញុំចង់ដឹង ដើម្បីនឹងអាលរៀបគរិយាបថអោយសមរម្យ ចំពោះគ្នានោះអី ។

- អីយ៉ា! ល្បងមានបំណងអ្វីហ្នឹង ?

- គ្មានអ្វីទេ គឺគ្រាន់តែសុំជាមិត្តប៉ុនហ្នឹងតើហ៎ ?

- ទើបតែស្គាល់គ្នាមិនបានមួយថ្ងៃផង មករកចងមេត្រីជាមិត្តជាបងប្អូនទៅហើយ... ដូចជារហ័សពេកទេនឹង ល្បង ? ការពិត ខ្ញុំមិនទាំងស្គាល់ល្បងផងថាជានរណាផង ! ជាមនុស្សអាក្រក់ល្អយ៉ាងណាក៏មិនដឹង ? វីវរ ល្បងទើបតែរត់ចេញពីគុក ប៉ូលីសកំពុងតាមរកមុខ នោះមិនសិយមិត្តភាពរបស់ខ្ញុំស្លាប់ហើយទេ ?

- អញ្ចឹង រាសីរៀនស្គាល់ខ្ញុំអោយជិតដិតទៅ... ប្អូននឹងបានដឹងដោយខ្លួនឯង ដោយមិនបាច់ខ្ញុំរៀបរាប់បរិយាយប្រាប់ច្រើនផង កុំអោយថា ខ្ញុំចេះតែកាន់ជើងខ្លួនឯង ។

រាសីលួចសម្លឹងមុខនរៈ ឃើញគេមានវ័យចាស់ជាងនាងច្រើនយ៉ាងហោចណាស់ក៏ដប់ឆ្នាំដែរ ។ មើលទៅគេ ទំនងជាមនុស្សគិតច្រើនហើយធ្វើការច្រើន ព្រោះឃើញគេលួចចងចញ្ចើមញឹកញាប់ថ្វីបើគេតែងតែញញឹមយ៉ាងស្រស់ចំពោះរូបនាងនៅរៀងរាល់ពេលដែលគេជួបនាងក៏ដោយ ។ បន្ទាប់មក នាងក៏ស្រដីថា ៖

- រាសីមិនខ្លាចនឹងរាប់ញាតិទេ តែបើញាតិហ៊ានលូកថ្លើមរាសីវិញនោះរាសីក៏មិនទុកមុខមាត់អោយឡើយ ល្បងនឹងហើយឬនៅ ?

- ដូច្នោះ ល្អណាស់ ដែលរាសីជាមនុស្សស្រវាស្រទេញរកមិត្តភឿនល្អៗសេពគប់ជាគ្នា ។ សយនាក៏នឹងមានគ្នីគ្នាល្អនឹងហៅរកផងដែរកុំអោយកណ្ដោចកណ្ដែងពេក ។ អញ្ចឹងថ្ងៃក្រោយ បើខ្ញុំមកលេងទៀត រាសីរាប់រកខ្ញុំផងណ៎ា !

- ហើយចុះនៅភ្នំពេញនោះ ល្បងគ្មានញាតិមិត្តទេ ?

- មានម្នាក់ពីរដែរ ! ប៉ុន្តែ អ្នកភ្នំពេញ ភាគច្រើនគេរាប់មនុស្សនឹងសន្លឹកដុល្លារ មិនមែនរាប់គ្នាដោយសារទឹកចិត្តរវាងគ្នានឹងគ្នា ដូចអ្នករស់នៅតាមស្រុកភូមិជនបទនោះទេណ៎ា ។



- អូហ៍ ! ហេតុអ្វីដល់ថ្នាក់ហ្នឹងផង ?

- ជីវិតនៅទីក្រុងធំ គឺដូច្នេះឯង ។ ញាតិជិតខាងផ្ទះមិនស្គាល់គ្នាឃើញញាតិហើយ មិនហ៊ានរាប់ ព្រោះមិនដឹងថា នរណាអាក្រក់នរណាល្អ... ម្នាក់ៗស្រវាស្រទេញរករស់តែរៀងៗខ្លួន គ្មាននរណាមានពេលគួរសមនឹងនរណាឡើយ ។

- បើដូច្នេះ រាសីត្រូវរៀនតាមចរិតអ្នកទីក្រុងហើយ កុំអោយមានសន្ដានចិត្តពេក ក្រែងច្រឡំយកដំរភ្លៅត្បៀតក្លៀក ។

បន្តិចមក សយនាក៏លារាសីចេញទៅវិញ ទាំងទឹកមុខញញឹមរីករាយ ចំពោះចំណងមិត្តភាពថ្មីរបស់គេ ។

នៅក្នុងបន្ទប់ជួល រាសីផ្ដេកក្បាលទៅលើខ្នើយ នឹកគិតក្នុងចិត្តតែម្នាក់ឯងថា ៖

- តើបុរសនេះជានរណា ? ហេតុអ្វីគេចង់មកចងនិស្ស័យ ជាមិត្តជាមួយយើងដែលជាមនុស្សចំណូលថ្មីទីនេះ ? តើគេមានគោលបំណងអាក្រក់ឬល្អ មកលើយើង ?... ដើម្បីប្រយោជន៍អ្វីដែរទៅកាលបើគេឃើញហើយតើ ថាយើងជាមនុស្សទីទ័លអត្ដខាត់បំផុតនោះ ?

oooooooooooooooooo

ooooo

o